# អ្នកនាំសារ
## The Messenger

40

ខែវិច្ឆិកា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



# និទានរឿងអំពីព្រះយេស៊ូនៅក្នុងទ្វីបអាស៊ី !



ចាកចោលភូមិ-ស្រុកកំណើតដើម្បីការងារ
ទំព័រ ៨



វិទ្យាស្ថានថ្មីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ
ទំព័រ ១១

គ្រិស្តបរិស័ទយកគំរូតាមមរណសាក្សី
ទំព័រ ១២

# សំនួរក្មេងៗ

## ស្វែងយល់ពាក្យក្នុងគម្ពីរ !




ប្អូនៗធ្លាប់បានឮពាក្យខ្លះ ដែលមានសរសេរក្នុងគម្ពីរ ដូចជា : ព្យាការី គ្រិស្ត គ្រិស្តទូត និងថ្ងៃសប្ប័ទ។ ពាក្យទាំងនេះមានន័យអ្វី ?

**ព្យាការី :** ជាអ្នកបម្រើព្រះជាម្ចាស់ និងថ្លែងព្រះបន្ទូលក្នុងនាមព្រះនាមព្រះជាម្ចាស់ ប្រាប់ប្រជាជន។ ព្យាការីដែលយើងធ្លាប់ស្គាល់ឈ្មោះ ដូចជា ព្យាការីអេលី ព្យាការីយេរេមី ព្យាការីអម៉ូស និងព្យាការីអេសាយ។ល។ ព្យាការីអេសាយមានឈ្មោះល្បីជាងគេក្នុងចំណោមព្យាការីទាំងអស់។ គ្រិស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ ហោរា។

**គ្រិស្ត (ព្រះ) :** ជាពាក្យក្រិក មានន័យថា "អ្នកដែលព្រះជាម្ចាស់ចាក់ប្រេង អភិសេកតែងតាំងជាស្តេច"។ ជនជាតិយូដាតែងហៅស្តេចអ៊ីស្រាអែលថា "ព្រះគ្រិស្ត" ដូច្នេះដែរ គឺមានព្រះបាទដាវីឌជាដើម។ ប៉ុន្តែពាក្យ "ព្រះគ្រិស្ត" នេះ សំដៅទៅលើស្តេចមួយអង្គ ដែលអ្នកស្រុកយូដាទន្ទឹងរង់ចាំព្រះអង្គយាងមកសង្គ្រោះពួកគេ តាមភាសាហេប្រឺ ពាក្យនេះហៅ "ព្រះមេស្ស៊ី"។

**គ្រិស្តទូត :** ជាសាវ័កមួយក្រុមដែលព្រះយេស៊ូតែងតាំងឱ្យធ្វើជាតំណាងព្រះអង្គ ហើយចាត់ឱ្យទៅប្រកាសផ្សាយដំណឹងល្អអំពីព្រះអង្គ។ កាលពីមុន ក្នុងគម្ពីរ មានប្រើពាក្យថាសាសនទូត។ គ្រិស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យសាវ័ក ឬអគ្គសាវ័កផងដែរ។

**ថ្ងៃសប្ប័ទ :** ជាថ្ងៃសៅរ៍។ ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ វិន័យបានបង្គាប់ឱ្យជនជាតិអ៊ីស្រាអែល ញែកថ្ងៃទីប្រាំពីរក្នុងសប្តាហ៍ ដែលគេហៅថា ថ្ងៃសប្ប័ទនេះ ទុកដោយឡែកដើម្បីគោរពបម្រើព្រះជាម្ចាស់ និងដើម្បីរំលឹកពីថ្ងៃដែលព្រះអង្គបង្កើតពិភពលោក។ នៅថ្ងៃសប្ប័ទ ជនជាតិអ៊ីស្រាអែលមិនត្រូវប្រព្រឹត្តធ្វើកិច្ចការអ្វីសោះឡើយ។

អ្នកនាំសារ

# អធិប្បាយព្រះបន្ទូល

### ថ្ងៃទី ០៥ វិច្ឆិកា ២០០៦ ត្រូវនឹងអាទិត្យទី ៣១ ប្រចាំឆ្នាំ "ខ"

## "ត្រូវស្រឡាញ់ព្រះអម្ចាស់ឱ្យអស់ពីចិត្ត"

(ម៉ាកុស ១២,២៨ខ-៣៤)

បងប្អូនខ្មែរ គ្រិស្តបរិស័ទ ឬពុទ្ធបរិស័ទ តែងចង់បានបុណ្យដោយខិតខំប្រព្រឹត្តតាមវិន័យទំនៀមទម្លាប់យ៉ាងតឹងរ៉ឹង។ សម័យព្រះយេស៊ូ ជនជាតិយូដាកាន់វិន័យច្រើនអនេក។ ជាពិសេស ពួកផារីស៊ីស្មានថាខ្លួនសុចរិតដោយការកាន់តាមវិន័យយ៉ាងម៉ត់ចត់។ ព្រះយេស៊ូរំឭកគេពីធម៌ ដែលគេធ្លាប់សូត្ររាល់ព្រឹកល្ងាច : "ត្រូវស្រឡាញ់ព្រះអម្ចាស់អស់ពីចិត្តគំនិត"។ តាមមតិគេ ពាក្យនេះមានន័យថា ត្រូវធ្វើកិច្ចការទាំងអស់ដោយគិតដល់ប្រយោជន៍ព្រះអង្គជានិច្ច "អស់ពីស្មារតី" គឺតម្រង់ជីវិតទាំងមូលទៅរកព្រះអង្គជាកំពូល "ឱ្យអស់ពីប្រាជ្ញា" និងនឹកគិតដល់ព្រះអម្ចាស់ជានិច្ច "អស់ពីកម្លាំងកាយ" បានសេចក្តីថា ត្រូវភ្ជាប់ចិត្តទៅនឹងព្រះអម្ចាស់គ្រប់ពេលវេលានិងគ្រប់កិច្ចការដែលខ្លួនធ្វើ។ តើនរណាអាចស្រឡាញ់តាមរបៀបនេះបាន? មានតែព្រះយេស៊ូមួយអង្គគត់ដែលបានស្រឡាញ់ព្រះបិតារបៀបនេះ។

"ត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឱ្យដូចជាស្រឡាញ់ខ្លួនឯង"។ ស្រឡាញ់ខ្លួនឯង មិនមានន័យថា ត្រូវរកប្រយោជន៍ផ្ទាល់ខ្លួនជាមុនទេ តែមានន័យថា ត្រូវរាប់ខ្លួនទុកជាមនុស្សមានតម្លៃ ព្រោះខ្លួនជាបុត្រធីតា



នៃព្រះបិតា។ ទោះបីខ្លួនជាអ្នកមានបាប គ្មានប្រាជ្ញា អ្នកក្រ ជរា ឬពិការក្តី ក៏ត្រូវបានរាប់ជាបុត្រធីតាជាទីស្រឡាញ់របស់ព្រះបិតា។ អ្នកមើលងាយខ្លួនឯង បន្ទាបបន្ថោកខ្លួន អ្នកនោះពុំស្រឡាញ់ព្រះបិតាដែលស្រឡាញ់ខ្លួននោះទេ។ មានតែអ្នកដែលរាប់ខ្លួនថា មានតម្លៃប៉ុណ្ណោះ ដែលអាចស្រឡាញ់អ្នកដទៃ ទុកជាបុត្រធីតារបស់ព្រះបិតាបាន។ ជីវិតអ្នកពិតជាមានតម្លៃ! មិនមែនទុក្ខំ អនិច្ចំ អនត្តាទេ!។

### ថ្ងៃទី ១២ វិច្ឆិកា ២០០៦ ត្រូវនឹងអាទិត្យទី ៣២ ប្រចាំឆ្នាំ "ខ"

## "ស្ត្រីមេម៉ាយក្រីក្ររូបនេះដាក់ប្រាក់នៅក្នុងហិបច្រើនជាងគេទាំងអស់"

(ម៉ាកុស ១២,៣៨-៤៤)

បងប្អូនពុទ្ធបរិស័ទ និងគ្រិស្តបរិស័ទក្រីក្រខ្លះ តែងតែត្អូញត្អែរថា ខ្លួនគេមិនអាចធ្វើបុណ្យកុសលបានទេ ពីព្រោះខ្លួនក្រីក្រពេកគ្មានលុយចូលបុណ្យសោះ។ រីឯអ្នកមាន និងអ្នកពុករលួយ គេអាចធ្វើបុណ្យបានច្រើន ពីព្រោះគេថ្វាយលុយច្រើន។ ថ្ងៃនេះព្រះយេស៊ូប្រៀនប្រដៅយើង តាមរបៀបប្លែកពីធម្មតា ព្រះពុទ្ធជាព្រះបរមគ្រូក៏បានប្រៀនប្រដៅដូច្នោះដែរ។ បុណ្យកុសលមិនសម្រេចលើទឹកលុយដែលខ្លួនថ្វាយនោះទេ គឺស្រេចតែចិត្តគំនិតអ្នកថ្វាយវិញ។ បើតាមគម្ពីរ ស្ត្រីមេម៉ាយគឺជាមនុស្សទន់ខ្សោយ គ្មានទីពឹង ហើយក្រីក្រជាងគេផងដែរ។ តែនាងយកតែពីរសេនមកថ្វាយនៅក្នុងព្រះវិហារ គឺនាងយកអ្វីទាំងអស់ដែលនាងទុកសម្រាប់ចិញ្ចឹមជីវិតមកថ្វាយវិញ។

តាមព្រះយេស៊ូ មិនបាច់ផ្សាយឱ្យគេដឹងថា យើងថ្វាយប្រាក់ប៉ុន្មាននោះទេ មិនបាច់កត់ឈ្មោះ និងចំនួនទឹកប្រាក់នៅលើជញ្ជាំងវត្ត តាមរបងសាលា ឬមួយក៏នៅក្នុងសៀវភៅសរសេរនោះទេ ព្រោះថា "ព្រះជាម្ចាស់ដែលគង់នៅទីសម្ងាត់នោះ ទ្រង់បានទតឃើញហើយ" (ម៉ាថាយ ៦,១-៤)។

ព្រះយេស៊ូក៏ដូចស្ត្រីមេម៉ាយរូបនេះដែរ គឺព្រះអង្គដាក់ខ្លួនទទួលទោសដូចជាជនឧក្រិដ្ឋដ៏ថោកទាបបំផុត



ដែលត្រូវគេសម្លាប់ យ៉ាងសែនអាម៉ាស់ និងមិនមានកិត្តិយសសោះឡើយ តែព្រះអង្គស្រឡាញ់ព្រះបិតាលើអ្វីទាំងអស់ក្នុងនាមយើង។ យើងថ្វាយកាយវាចាចិត្តទៅរកព្រះបិតាដោយការរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ។ យើងក្លាយទៅជាសក្ការបូជាខាងវិញ្ញាណ។



### ថ្ងៃទី ១៩ វិច្ឆិកា ២០០៦ ត្រូវនឹងអាទិត្យទី ៣៣ ប្រចាំឆ្នាំ "ខ"

## "ថ្ងៃកំណត់ គ្មាននរណាដឹងឡើយ"

(ម៉ាកុស ១៣,២៤-៣២)

ជិតដល់ចុងឆ្នាំខាងពិធីបុណ្យ។ នៅថ្ងៃអាទិត្យនេះ អត្ថបទគម្ពីរនាំឱ្យយើង រិះគិតពីដំណើរការនៃប្រវត្តិសាស្ត្រមនុស្សលោករហូតដល់ថ្ងៃអវសានកាលនៃពិភពលោក។

យើងជាគ្រិស្តបរិស័ទ រង់ចាំព្រះគ្រិស្តយាងមកវិញ ប្រកបដោយសិរីរុងរឿង។ សព្វថ្ងៃនិកាយគ្រិស្តបរិ-ស័ទខ្លះទន្ទឹងរង់ចាំព្រះគ្រិស្តយាងមកវិញជាខ្លាំង។ ជួនកាលគេហ៊ានទស្សន៍ទាយនូវថ្ងៃព្រះអង្គយាងមកទៀតផង។ តែព្រះយេស៊ូទូន្មានថា គ្មាននរណាដឹងឡើយ សូម្បីតែព្រះបុត្រាក៏ព្រះអង្គមិនជ្រាបដែរ។

តាមពិតព្រះយេស៊ូប្រៀនប្រដៅយើងឱ្យប្រុងប្រយ័ត្នទទួលព្រះអង្គជានិច្ច។ ព្រឹត្តិការណ៍ទាំងអស់ ដែលកើតក្នុងការរស់នៅរបស់ខ្លួនផ្ទាល់ ក្នុងប្រទេសយើង នៅក្នុងពិភពលោក ទាំងគ្រោះកាចធម្មជាតិ ទាំងសង្គ្រាម ក៏សុទ្ធតែជាពេលឱ្យយើងត្រូវប្រុងខ្លួនទទួលព្រះគ្រិស្តដែលយាងមក គឺឱ្យយើងប្រែចិត្តគំនិតផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ និងធ្វើជាសាក្សីពីជំនឿរបស់ខ្លួន។ ដូចនៅសម័យប្រល័យពូជសាសន៍ ប៉ុល ពត ជំនឿរបស់គ្រិស្តបរិស័ទខ្លះក៏កាន់តែមាំមួនឡើង។ នៅពេលដែលមានកូនកើតមកក្នុងគ្រួសារ



គឺប្រៀបដូចជា ព្រះយេស៊ូយាងមកប្រសូតជាមនុស្សដែរ។ នៅពេលរៀបអាពាហ៍ពិពាហ៍ គឺហាក់ដូចជាព្រះបិតាសម្តែងព្រះហឫទ័យស្រឡាញ់មកកាន់យើង។ នៅពេលមានបងប្អូនមិត្តសម្លាញ់ទទួលមរណភាព គឺយើងរិះគិតអំពីតម្លៃនៃជីវិតរួមជាមួយព្រះជាម្ចាស់។ល។

### ថ្ងៃទី ២៦ វិច្ឆិកា ២០០៦ ត្រូវនឹងអាទិត្យទី ៣៤ ប្រចាំឆ្នាំ "ខ"
### គឺថ្ងៃគោរពព្រះគ្រិស្ត ជាព្រះមហាក្សត្រនៃពិភពលោក

## "រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ"

(យ៉ូហាន ១៨,៣៣ខ-៣៧)

តាំងពីពេលខ្មាំងសត្រូវកៀរប្រជាជនយូដាធ្វើជាឈ្លើយ និងធ្វើគុតព្រះមហាក្សត្ររបស់គេ គេនាំគ្នារង់ចាំស្តេចមួយអង្គ ដែលគេហៅថា "ព្រះគ្រិស្ត" តាមព្រះនាមព្រះមហាក្សត្រស្រុកគេ។ គេសង្ឃឹមថាស្តេចនោះនឹងយាងមករំដោះស្រុកគេឱ្យមានសេរីភាពឡើងវិញ។ ជនជាតិយូដាតែងតែទន្ទឹងរង់ចាំ ព្រះគ្រិស្ត យាងមកគ្រងរាជ្យ ក្នុងនាមព្រះជាម្ចាស់ ឬរង់ចាំព្រះជាម្ចាស់យាងមកគ្រងរាជ្យដោយផ្ទាល់ព្រះអង្គ គេហៅព្រឹត្តិការណ៍នោះថា "ព្រះរាជ្យរបស់ព្រះជាម្ចាស់"។

ជនជាតិយូដាចាប់លោកយេស៊ូ គេចោទថាលោកតាំងខ្លួនជាព្រះមហាក្សត្ររបស់ជនជាតិយូដា (គឺ "ព្រះគ្រិស្ត") ដែលដណ្តើមអំណាចពីព្រះចៅអធិរាជរ៉ូម៉ាំងតាមអាវុធ ឬនយោបាយ។ ពេលព្រះយេស៊ូទទួលព្រះជន្មដ៏រុងរឿង សាវ័កប្រកាសថា លោកយេស៊ូពិតជាព្រះគ្រិស្ត ពិតជាព្រះមហាក្សត្រ ដែលធ្វើឱ្យព្រះបន្ទូលសន្យាព្រះជាម្ចាស់កើតជារូបរាង។ ព្រះអង្គនាំសេរីភាព និងសេចក្តីសុខសាន្តដ៏ពិតប្រាកដឱ្យគេ។ ព្រះយេស៊ូមិនមែនជាព្រះមហាក្សត្រតាមនយោបាយក្នុងលោកនេះទេ តែព្រះអង្គយាងមក "ផ្តល់សក្ខី



ភាពអំពីសេចក្តីពិត" គឺផ្តល់ដំណឹងល្អ ពីព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះបិតា ដែលស្រឡាញ់មនុស្សលោករហូតដល់ទីបំផុត ដោយទ្រង់សុខចិត្តបូជាជីវិត។ បើតាមប្រវត្តិសាស្ត្រ ព្រះសហគមន៍បានលំអៀងខ្លះទៅកាន់អំណាចនយោបាយ។ ប៉ុន្តែតាមការពិតព្រះសហគមន៍ គឺមានតែអំណាចនៃសេចក្តីស្រឡាញ់ប៉ុណ្ណោះ។

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !**



## សូមនិទានអំពីរឿងព្រះយេស៊ូ !

រឿងអំពីព្រះយេស៊ូ គឺជារឿងនៃសេចក្តីពិតដែលផ្តល់សេចក្តីសង្ឃឹមដល់មនុស្សគ្រប់រូប។ តើត្រូវនិទានរឿងព្រះយេស៊ូយ៉ាងដូចម្តេច ? ការនិទានរឿងព្រះយេស៊ូ គឺខុសពីការនិទានរឿងប្រលោមលោក។ ការនិទាននេះប្រែជាការចែកបទពិសោធន៍អំពីព្រះយេស៊ូវិញ។ ក្នុងមហាសន្និបាតបេសកកម្មព្រះសហគមន៍នៅទ្វីបអាស៊ីនៅក្រុងឈៀងម៉ៃ ប្រទេសថៃ គេបានរិះគិតច្រើនអំពីរបៀបដែលត្រូវនិទានរឿងពីព្រះយេស៊ូស្របតាមវប្បធម៌នៃទ្វីបអាស៊ី និងតាមប្រពៃណីប្រទេសនីមួយៗ ដូចអ្វីដែលមហាសន្និបាតវ៉ាទីកង់ ទី២ បានអនុញ្ញាតឱ្យប្រើប្រពៃណីវប្បធម៌របស់ជនជាតិនីមួយៗ ដើម្បីលើកតម្កើងព្រះជាម្ចាស់។

ការចែកបទពិសោធន៍អំពីព្រះយេស៊ូ គឺការលះបង់ដើម្បីបម្រើអ្នកដទៃ ការរស់រួមជាមួយបងប្អូន ដោយសេចក្តីស្រឡាញ់នៅក្នុងការរស់នៅរបស់យើងគ្រប់គ្នា ការគោរពគ្នាទៅវិញទៅមក។ ការចែកបទពិសោធន៍តាមរយៈកិច្ចប្រចាំថ្ងៃ មានកម្លាំងខ្លាំងជាងការចែករំលែកត្រឹមតែពាក្យសំដី។ ការរស់នៅតាមព្រះបន្ទូលពិតជាមានការលំបាក តែសូមយើងពឹងផ្អែកនៅលើព្រះវិញ្ញាណដែលគង់នៅជាមួយយើងគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់។ លោកអភិបាល ពេទ្រ ង៉យិន វ៉ាន់តៃ បានលើឧទាហរណ៍មួយពន្យល់ក្នុងមហាសន្និបាតបេសកកម្មអាស៊ីកន្លងទៅនេះថា : "ស្រូវវ៉ាងាប់ដើម្បីបង្កើតផលផ្លែ ហើយផលផ្លែស្រូវត្រូវប្រែក្លាយទៅជាអង្ករ ហើយអង្ករងាប់ទៅទៀតដើម្បីក្លាយទៅជាបាយសម្រាប់មនុស្សបរិភោគចិញ្ចឹមជីវិត"។ តើខ្ញុំសព្វថ្ងៃបានធ្វើអ្វីខ្លះជាសាក្សីអំពីព្រះយេស៊ូ ? តើខ្ញុំនិទានរឿងអំពីព្រះយេស៊ូយ៉ាងដូចម្តេចប្រាប់អ្នកជិតខាងខ្ញុំ ?

លី សុវណ្ណា

## CD ចម្រៀង និងល្ខោន អំពីកំណើតព្រះយេស៊ូ

ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតឆ្នាំ២០០៦នេះ មណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកមានផលិត CD ចម្រៀង និងល្ខោននិយាយអំពីជីវៈប្រវត្តិរបស់ព្រះយេស៊ូប្រសូត។ ប្រសិនបើបងប្អូនមានចំណាប់អារម្មណ៍នោះ សូមអញ្ជើញចូលរួមជាវដោយទាក់ទងមកកាន់ការិយាល័យយើងខ្ញុំ។ ទូរស័ព្ទ: ០២៣ ២២៤ ១២០ ឬ០១២ ២៤៤ ៧៧៨។

សូមអរគុណ!

## សន្និបាតក្រុម PASTORAL ឆ្នាំ២០០៦

នេះគឺជាការប្រជុំលើកទី៧ របស់ក្រុមបូជាចារ្យ បងស្រីគណៈកម្មការព្រះសហគមន៍ និងដៃគូ អង្គការកាតូលិកនៃភូមិភាគបាត់ដំបង ចាប់ពីថ្ងៃទី២៥-២៧ ខែតុលា ឆ្នាំ២០០៦នេះ នៅព្រះសហគមន៍សៀមរាប។

ក្នុងនោះ មានការចូលរួមពីបូជាចារ្យចំនួន៩នាក់ បងស្រី២៥នាក់ គណៈកម្មការព្រះសហគមន៍១០នាក់ និងដៃគូអង្គការកាតូលិក១០នាក់ដែរ។ ការប្រជុំពិភាក្សានេះធ្វើឡើង ដើម្បីចែករំលែកបទពិសោធន៍ ក្នុងការបម្រើព្រះសហគមន៍ និងប្រជាជនក្រីក្រ ការដោះស្រាយបញ្ហាក្នុងការងារ ព្រមទាំងរិះគិតអំពីការបង្កើតមណ្ឌលប្រឹក្សាភិបាលកិច្ចថ្មីមួយប្រចាំភូមិភាគបាត់ដំបង (Pastoral)។

គោលដៅ៤ចំនុច ដែលលោកអភិបាលដាក់ចេញ នៅក្នុងអង្គប្រជុំ គឺមានការអធិដ្ឋាន ការទទួលស្គាល់ពីជំនឿនៃគ្រិស្តបរិស័ទលើព្រះជាម្ចាស់ ការវាយតំលៃសកម្មភាពដែលគ្រិស្តបរិស័ទកំពុងធ្វើ និងការធ្វើផែនការអនាគត។

សុជាតិ



Photo: Fr. Totet

## ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ

ប្អូនៗជាទីស្រឡាញ់!

កាលពីខែឧសភា កន្លងទៅនេះ យើងខ្ញុំបានផ្ញើឯកសារមួយចំនួនទៅដល់អស់លោកបូជាចារ្យ និងបងស្រីនៅក្នុងភូមិភាគភ្នំពេញ ទាក់ទងទៅនឹងកម្មវិធីបណ្តុះបណ្តាលដែលរៀបចំឡើងដោយសមាគម Fondacio នៅក្នុងប្រទេសហ្វីលីពីន។

កម្មវិធីនេះជួយបណ្តុះបណ្តាលក្នុងរយៈពេល១ឆ្នាំ ដល់យុវជនគ្រិស្តបរិស័ទកាតូលិក ដែលមានគោលបំណងចង់បម្រើព្រះសហគមន៍។

ជាថ្មីម្តងទៀត យើងខ្ញុំសូមទទូចចង់ឱ្យកម្មវិធីនេះទទួលបានជោគជ័យតាមរយៈការប្តេជ្ញាចិត្តដ៏ខ្ពស់បំផុត។ នៅក្នុងឆ្នាំសិក្សា២០០៧-២០០៨ កម្មវិធីបណ្តុះបណ្តាលនេះផ្តល់ជូនដល់យុវជនចំនួន ៣រូប ដែលកំពុងរស់នៅ ឬស្នាក់អាស្រ័យក្នុងភូមិភាគភ្នំពេញបច្ចុប្បន្ន ហើយដែលមានគោលបំណងបម្រើព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលយ៉ាងហោចណាស់រយៈពេល ២ឆ្នាំ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលរបស់ខ្លួន។

យើងដឹងថា មានយុវជនច្រើននៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងព្រះសហគមន៍។ នេះជាមូលហេតុធ្វើឱ្យព្រះសហគមន៍ភូមិភាគភ្នំពេញចង់បើកផ្លូវមួយដើម្បីធ្វើឱ្យសកម្មភាពយុវជនមានការរីកចម្រើនឡើងនាពេលអនាគត។

ប្អូនៗអាចរកមើលឯកសារដែលបានភ្ជាប់មកជាមួយនិងព័ត៌មានខ្លះៗ និងកម្មវិធីសិក្សារបស់ Fondacio។ សូមប្អូនៗកត់សម្គាល់ថា សំណុំបែបបទនៃពាក្យស្នើសុំនេះចាំបាច់ត្រូវមានការយល់ព្រមអំពីលោកបូជាចារ្យ ដែលប្អូនៗស្គាល់នៅក្នុងព្រះសហគមន៍របស់ប្អូនៗ ឬទីកន្លែងដែលប្អូនៗកំពុងរស់នៅ។

សូមប្អូនៗ បំពេញសំណុំបែបបទពាក្យស្នើសុំចូលរៀននេះជាភាសាអង់គ្លេស ហើយផ្ញើជូនលោកបូជាចារ្យប្រ៊ុយណូវិញឱ្យបានមុនថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ជាកំហិត។

សូមព្រះជាអម្ចាស់ប្រទានពរឱ្យប្អូនៗទាំងអស់គ្នា និងប្រទានពរដល់គ្រប់កិច្ចការរបស់ប្អូនៗនៅក្នុងព្រះសហគមន៍។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៦

លោកបូជាចារ្យប្រ៊ុយណូ លោកបូជាចារ្យអាស្តី


## អេម៉ានូអែល

សំឡេងពីព្រះសហគមន៍កាតូលិក!



បាត់ដំបង: FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

កំពង់ធំ: FM 107.3 Mhz
ម៉ោង ៥:៣០-៦:០០ រាល់យប់ថ្ងៃសៅរ៍។






## មណ្ឌលតម្បាញសូត្រចំការទៀងចែកវិញ្ញាបនបត្រ



Photo: Choeun

កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៦ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសន្តប្រាំង់ស្វ័រ ព្រះសហគមន៍ចំការទៀង ខេត្តតាកែវ បានប្រារព្ធពិធីប្រគល់វិញ្ញាបនបត្រឱ្យដល់សិក្ខាកាមចំនួន២៥នាក់ ផ្នែកតម្បាញសូត្រខ្មែរក្រោមអធិបតីភាពនៃឯកឧត្តម អ្នកឧកញ៉ាច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ តំណាងអង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ ហើយនិងប្រជាពលរដ្ឋប្រមាណ ៣០០នាក់។ ឆ្លៀតនៅក្នុងឱកាសនោះ លោកឪពុកអូលីវីយេ អ្នកទទួលខុសត្រូវព្រះសហគមន៍ ចំការទៀង ក៏មានប្រសាសន៍ក្នុងទឹកមុខញញឹមថា: "មណ្ឌលសិប្បកម្មតម្បាញសូត្រនេះបង្កើតឡើងតាំងពីឆ្នាំ២០០៣មក គឺក្នុងគោលបំណងឱ្យប្រជាជនខ្មែរបង្កើននូវសមត្ថភាពថែរក្សាប្រពៃណីវប្បធម៌របស់ខ្លួន និងជាពិសេសដើម្បីឱ្យពួកគេមានការងារធ្វើគ្រប់ៗគ្នា"។

ជាមួយគ្នានេះ កញ្ញាជ្រាយ សាវ៉ន អាយុ ២១ឆ្នាំ ជាសិក្ខាកាមមណ្ឌលនេះ ក៏បានសម្តែងក្តីសប្បាយរីករាយ ដែលកញ្ញាបានទទួលជោគជ័យ និងមានស្នាដៃល្អរហូតទទួលនូវវិញ្ញាបនបត្រ។ កញ្ញាបានឱ្យដឹងថា: "ខ្ញុំដែលមានថ្ងៃនេះ គឺដោយសារព្រះសហគមន៍ ពិសេសមានលោកឪពុកអូលីវីយេ បងប្រុស ហេរ្ឈម រូហ្វិអេ និងអ្នកគ្រូ ធូ ហាង ដែលពួកគាត់ បានជួយជ្រោមជ្រែង លើកទឹកចិត្ត ផ្តល់ឱកាស លទ្ធភាពនិងក្តីសង្ឃឹមដល់រូបខ្ញុំ ក៏ដូចមិត្តភ័ក្តិ ឱ្យខិតខំព្យាយាមសិក្សា និងមានសមត្ថភាពត្បាញសូត្រដល់កម្រិតស្តង់ដារអន្តរជាតិ"។

មណ្ឌលតម្បាញសូត្រខ្មែរព្រះសហគមន៍កាតូលិកចំការទៀង បានបង្ហាញអំពីស្នាដៃសិប្បកម្មខ្មែរ ដ៏រស់រវើកពិតៗនៃទឹកដៃកូនខ្មែរនៅជនបទ ហើយផលិតផលដ៏ប្រណីតនេះកំពុងត្រូវបានលក់យ៉ាងគគ្រឹកគគ្រេងនៅក្នុង និងក្រៅប្រទេសផងដែរ។

បើសិនសម្តេច ទ្រង់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ចាប់អារម្មណ៍ សូមទាក់ទងហាងលក់ស្នាដៃ តម្បាញសូត្រផ្កា "តាមចិត្ត" នៅផ្ទះលេខ៣ ផ្លូវទី៣ សុធារស ក្រុងភ្នំពេញ ទូរស័ព្ទ: ០១២ ៧៣៦ ១៩២។

យុន សំអាត

## កសិកម្មថ្មីនៅភូមិកោះរកា

កំពុងកាប់ដីបែកញើសជោគខ្លួន នាម ធាន់ ដែលធ្វើចំការនៅលើដីថ្មីនេះជាងមួយឆ្នាំមកហើយ បាននិយាយថា: "យើងមានមនុស្សចំនួន៩នាក់ ធ្វើចំការនៅលើដីនេះ។ ម្នាក់ៗ ទទួលកម្រៃ ៦០០០រៀល ក្នុងមួយថ្ងៃ"។ ក្រៅពីការងារក្នុងព្រះសហគមន៍ ស្ត្រីរូបនេះគ្មានការងារអ្វីធ្វើផ្សេងទៀតទេ។ គាត់បានប្រាប់ទៀតថា ឆ្នាំកន្លងទៅនេះ គាត់បានទទួលប្រាក់ចំនួន ៦០ម៉ឺនរៀល ដោយមិនបូកបញ្ចូលកម្រៃប្រចាំថ្ងៃទេ។

លោកសុគុណ អ្នកមើលការខុសត្រូវជីកសិកម្មនេះ មានប្រសាសន៍ថា ព្រះសហគមន៍កោះរកាទើបនឹងចាប់ផ្តើមធ្វើកសិកម្មបានមួយឆ្នាំតែប៉ុណ្ណោះ។ យើងបានជួលដីអ្នកភូមិនៅទីនេះក្នុងមួយឆ្នាំ ២៥ម៉ឺនរៀល ហើយអាចដាំបន្លែបាន ៤ដង។ ថវិកាដែលទទួលបានក្នុងឆ្នាំដំបូង ព្រះសហគមន៍បានចែកដល់បងប្អូនដែលធ្វើការងារនៅទីនេះទាំងអស់



Photo: K. Kagnha

ពីព្រោះភាគច្រើនពួកគេជាអ្នកខ្វះខាត និងស្ត្រីមេម៉ាយ ដែលគ្មានដីសម្រាប់បង្កបង្កើនផល។

កញ្ញា

## យុវជនជុំគីរីទទួលជំហានទី១



Photo: Choeun

យុវជនចំនួន២៧នាក់ នៅជុំគីរី ខេត្តកំពត បានទទួលជំហានទី១ នៃអគ្គសញ្ញាជ្រមុជទឹកដើម្បីចូលព្រះសហគមន៍ រៀបចំឡើងដោយលោកបូជាចារ្យសួន ហង្សលីជាអ្នកទទួលខុសត្រូវព្រះសហគមន៍ជុំគីរី ដោយមានការចូលរួមពីលោកបូជាចារ្យអូលីវីយេ និងយុវជនច្រើននាក់ទៀត។ កម្មវិធីនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី៨ តុលា ឆ្នាំ២០០៦កន្លងទៅ។ លោកហម តឿ គ្រូអប់រំជំនឿ មានប្រសាសន៍ថា: "ខ្ញុំសម្រេចចិត្តឱ្យយុវជនទាំងនោះទទួលអគ្គសញ្ញាជ្រមុជទឹកព្រោះពួកគេមានជំនឿ ហើយខិតខំស្វែងយល់ពីព្រះគម្ពីរនិងព្រះបន្ទូលយ៉ាងយកចិត្តទុកដាក់"។ លោកបន្តថា ពួកគេចេះជួយគ្នា សួរសុខទុក្ខអ្នកក្រីក្រ អ្នកជំងឺ ជាពិសេស ពួកគេចេះសម្តែងធម៌មេត្តាករុណា អំពើល្អ និងប្រកបដោយគុណធម៌ដល់បងប្អូនឯទៀតៗ។

កញ្ញាឡៀ សេដ្ឋា ជាយុវនារីទទួលអគ្គសញ្ញាជ្រមុជទឹកជំហានទី១ បានសម្តែងនូវសេចក្តីរីករាយដែលបានចូលព្រះសហគមន៍ ហើយបានប្តេជ្ញាចិត្តខិតខំសិក្សាស្វែងយល់ព្រះគម្ពីរ និងព្រះបន្ទូលបន្តដើម្បីក្លាយជាគ្រូអប់រំជំនឿក្នុងក្រុមសង្គហៈ ឬក្រុមមេត្តាករុណាដើម្បីបង្ហាញនូវមេត្តាធម៌អំពើល្អ ដែលបានមកពីអំណោយទានរបស់ព្រះជាម្ចាស់ ដល់បងប្អូន [illegible]

យុន សំអាត

# និទានអំពីប្រវត្តិរបស់ព្រះយេស៊ូនៅក្នុងទ្វីបអាស៊ី

**ក្រុមបព្វជិត បព្វជិត អ្នកស្ម័គ្រចិត្តប្រមាណជាង១០០០នាក់ និងអ្នកអង្កេតការប្រមាណជាង១០០នាក់ ដែលមកពីប្រទេសផ្សេងៗ បានជួបជុំគ្នានៅក្នុងអង្គសន្និបាតបេសកកម្មរបស់ព្រះសហគមន៍នៅទ្វីបអាស៊ី ដែលបានប្រព្រឹត្តចាប់តាំងពីថ្ងៃទី១៨-២២ ខែតុលា ឆ្នាំ២០០៦ នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ។ ចំណែកកម្ពុជាក៏មានតំណាង២៦រូប ដឹកនាំលោកអភិបាល និងអភិបាលរងភូមិភាគទាំងបីចូលរួមផងដែរ។**









Photos: L. Sovanna

អង្គសន្និបាតនេះបានរិះគិតលើប្រធានបទតាមថ្ងៃនីមួយៗ គឺដូចជា ប្រវត្តិព្រះយេស៊ូក្នុងជីវិតយើង ប្រវត្តិព្រះយេស៊ូចំពោះប្រជាជន ដែលមានជំនឿផ្សេងៗ និងប្រវត្តិព្រះយេស៊ូក្នុងវប្បធម៌អាស៊ី។ ដោយតាំងចិត្តនាំឱ្យអ្នកដទៃស្គាល់ អំពីព្រះយេស៊ូតាមរបៀបអាស៊ី។ រឿងរ៉ាវរបស់ព្រះយេស៊ូ មិនមែនគ្រាន់តែជារឿងធម្មតា គឺជារឿងរ៉ាវនៃជីវិតពិតប្រាកដដែលផ្ដល់នូវសេចក្ដីសង្ឃឹមដល់យើង។ ការនិទានអំពីប្រវត្តិព្រះយេស៊ូនៅពេលនេះ គឺជាការចែករំលែកបទពិសោធន៍អំពីព្រះយេស៊ូ។

លោកអភិបាល ល្វីស អន់តូនីញ៉ូ មកពីប្រទេសហ្វីលីភីន មានប្រសាសន៍ថា: "ការនិទានពីប្រវត្តិព្រះយេស៊ូនៅទ្វីបអាស៊ី គឺព្រះសហគមន៍ត្រូវការរួមជាមួយព្រះយេស៊ូក្នុងការអធិដ្ឋាន និងរស់នៅរួមជាមួយ ប្រជាជនទាំងអស់ ដោយក្ដីស្រលាញ់ ជាពិសេសអ្នកក្រីក្រ អ្នកជំងឺ និងអ្នកគ្មានទីពឹង"។ ដួនជីសិរីបុន ពុទ្ធចាន់ណាទំរុងពង្ស ជាជនជាតិថៃ បានចែករំលែកនូវបទពិសោធន៍ ដែលនាំឱ្យទទួលស្គាល់ព្រះយេស៊ូ ក្នុងជីវិតរបស់បងស្រីថា: "គឺជាការមើលឃើញពីគំរូនៃការរស់របស់គ្រិស្តបរិស័ទក្នុងភូមិ ដែលរស់នៅតាមព្រះបន្ទូលព្រះយេស៊ូ"។ ទោះបីអ្នកទាំងនោះមិនដែលនិយាយពីព្រះបន្ទូលរបស់យេស៊ូក៏ដោយ។ ដូនជីរូបនេះ ក៏បន្តថា តាមរយៈសេចក្ដីស្រលាញ់ វាផ្ដល់ឱ្យបងប្អូនទាំងនោះមាននូវសេចក្ដីសង្ឃឹម និងកម្លាំងចិត្តដើម្បីបម្រើអ្នកដទៃ ដែលនេះជាចំនុច នាំឱ្យបងស្រីចង់ក្លាយជាគ្រិស្តបរិស័ទ និងធ្វើជាដូនជីផងដែរ។ លោកនីថាត ជនជាតិថៃ ក៏យល់ស្របចំពោះដូនជីសិរីបុនដែរដោយគាត់បានបញ្ជាក់ថា: "សកម្មភាពរបស់យើងគឺមានកម្លាំងខ្លាំង ជាជាងការនិយាយដោយផ្ទាល់មាត់អំពីការសង្គ្រោះ ឬសេចក្ដីស្រលាញ់មកពីព្រះជាម្ចាស់ជាបិតានៃយើង"។ លោកបន្តទៀតថា យើងត្រូវរស់នៅឱ្យស្របតាមព្រះបន្ទូល និងស្របតាមការរស់នៅរបស់បងប្អូនជិតខាង។ "ការរស់នៅរបស់គ្រិសបរិស័ទដែលចេះស្របខ្លួនទៅតាមវប្បធម៌ របស់ប្រជាជនក្នុងតំបន់ ជាការប្រកាសព្រះបន្ទូលផងដែរ" ទាំងនេះជាសំដីរបស់លោកបូជាចារ្យសំ ផង់ ជនជាតិថៃ។ លោកបានសង្កត់ធ្ងន់ថា: "ព្រះសហគមន៍នៅអាស៊ីគឺត្រូវតែចេះនិទានរឿងអំពីព្រះយេស៊ូ តាមរបៀបនៃការរស់នៅរបស់អាស៊ី និងវប្បធម៌របស់ខ្លួន"។

លី សុវណ្ណា

## ចំនួនអ្នកចូលរួមអង្គសមាជ

លោកកាឌីណាល់៥រូប លោកអគ្គអភិបាល ១៨រូប លោកអភិបាល៦៤រូប។ លោកបូជាចារ្យ ៣៧០រូប លោកឧបដ្ឋាក់ម្នាក់ អ្នកស្ម័គ្រចិត្តប្រុសស្រី៣៩៦នាក់ ក្រុមបងស្រី ១៧៣នាក់ និងក្រុមបងប្រុស២០នាក់។ សរុបប្រមាណ ១០៤៧នាក់ ដែលមកពី ២២ប្រទេសក្នុងទ្វីបអាស៊ី មាន: កម្ពុជា បង់ក្លាដែស ប្រ៊ុយណេ ទីម័រខាងកើត ហុងកុង ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន កាហ្សាស្ថាន ឡាវ ម៉ាកាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ភូមា ណេប៉ាល់ ប៉ាគីស្ថាន ហ្វីលីភីន សាំងហ្គាពួរ កូរ៉េខាងត្បូង ស្រីលង្កា កោះតៃវ៉ាន់ និងប្រទេសថៃ។





# ២០ឆ្នាំឆ្ងាយ ឃ្លាតឆ្ងាយពីស្រុកកំណើត និងការជួបជុំ

លោកសំ រុន ជាជនជាតិខ្មែរ បានចាកចេញពីប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៩ ដោយសារសង្គ្រាម សព្វថ្ងៃនេះលោកជាតែកុងនាវាចម្លងនៅប្រទេសបារាំង។ លោកធ្វើដំណើរទៅដល់ទីក្រុងប៉ារីសនៅថ្ងៃគេប្រារព្ធពិធីបុណ្យណូអែលនាឆ្នាំ១៩៨០។ លោកសំ រុន មានប្រសាសន៍ថា: "ខ្ញុំហាក់ដូចជាមានសំណាងដែរ ដោយមានគ្រួសារវៀយចំណាស់មួយបានទទួលលោកទៅចិញ្ចឹម"។ តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ នេះជាលើកទីមួយហើយដែលលោកបានមកប្រទេសកម្ពុជា។ លោកគូសបញ្ជាក់ថា: "នៅក្នុងចិត្តរបស់ខ្ញុំ នៅតែនឹកជានិច្ចនូវឈ្មោះភ្នំរូងដែលជាភូមិកំណើតរបស់ខ្ញុំក្នុងខេត្តតាកែវ"។ មុនពេលលោកមកដល់ភ្នំពេញនាថ្ងៃទី២៣ តុលា ឆ្នាំ ២០០៦ លោកមានទំនាក់ទំនងជាមួយលោកឪពុកអូលីវីយេ ព្រមទាំងផ្ទះសមាជិកជនបរទេសនៅភ្នំពេញជាច្រើនរូបទៀត។ ប៉ុន្តែអ្នកដែលសំខាន់ក្នុងការជួយលោកស្វែងរកក្រុមគ្រួសារ គឺអ្នកស្រីលក្ខិណា ដែលនិយាយភាសាបារាំងបានយ៉ាងល្អ និងជាមិត្តភ័ក្តនៃផ្ទះសមាជិកជនបរទេស និងជាបុគ្គលិកនៃអង្គការគ្រួសារថ្មីផងដែរ។ ដោយសារជំនួយពីពួកគេ លោកបានជួបឪពុកម្ដាយ និងបងប្អូនលោកឡើងវិញ លោកហាក់ដូចជាបិតនៅក្នុងសុបិន ដោយលោកបានជួបគ្រួសារលោកទាំងអស់ មានម្ដាយឪពុក និងបងប្អូនប្រុសស្រីរបស់លោកជាដើម។ លោកគិតថា ត្រូវរក្សាការទាក់ទងជាមួយពួកគេ ទោះជាលោករស់នៅឆ្ងាយសែនឆ្ងាយពីពួកគេក៏ដោយ។ លោកនឹងត្រឡប់មកវិញនៅខែមេសាឆ្នាំក្រោយ។

ផាត សំភី



Photo: P. Samphy

លោកសំ រុន



Photo: S. Philong

បុណ្យអុំទូកជាប្រពៃណីខ្មែរដ៏ផូរផង់

# ប្រវត្តិពិធីបុណ្យអុំទូក ប្រពៃណីជាតិ

ពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ ជាពិធីបុណ្យប្រពៃណីជាតិមួយ ដែលត្រូវបានប្រជាជនខ្មែរប្រារព្ធធ្វើជារៀងរាល់ឆ្នាំ រយៈពេល៣ថ្ងៃ ដោយគិតតាមប្រតិទិនចន្ទគតិ គឺនៅថ្ងៃទី១៤ ១៥កើត និង១រោច ខែកត្តិក។ ការប្រារព្ធធ្វើនៅខែនេះ គឺយោងទៅតាមលក្ខខណ្ឌធម្មជាតិនៃអាកាសធាតុ ក៏ដូចជារដូវកាលខែកត្តិក ជាពេលវេលា ដែលទឹកទន្លេមេគង្គចាប់ផ្ដើមស្រកចុះបណ្ដើរៗ (រដូវទឹកសម្រក) ដែលបង្កលក្ខណៈងាយស្រួលក្នុងការប្រកួតប្រជែងចែវទូកយ៉ាងសប្បាយរីករាយរបស់ប្រជាជនកម្ពុជា។

ពិធីប្រណាំងទូកត្រូវបានធ្វើឡើងដើម្បីជានិមិត្តរូប ក៏ដូចជាការរំឭកគុណដល់កងទ័ពជើងទឹកខ្មែរ ដែលធ្លាប់មានមហិទ្ធិឫទ្ធិដ៏ខ្លាំងក្លាពូកែក្នុងការការពារបូរណភាពដែនដី ឱ្យរួចផុតពីការឈ្លានពានរបស់សត្រូវ។ មានប្រភពផ្សេងៗគ្នាដែលបញ្ជាក់ពីប្រភពកំណើតនៃពិធីប្រណាំងទូកនេះ។ ទី១ នៅសម័យអង្គរ នាស.វទី១២ ក្រុងកម្ពុជាមានសេចក្ដីសុខក្សេមក្សាន្តរុងរឿងណាស់ ដោយព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ចេញធ្វើសឹកសង្គ្រាមជើងទឹកបង្ក្រាបពួកចាម ដោយកងទ័ពទូកចម្បាំងរំដោះ ក្រុងកម្ពុជាឱ្យរួចផុតស្រឡះចេញពីខ្មាំងសត្រូវ (គ.ស ១១៧៧-១១៨១)។ ទី២ នៅសម័យលង្វែក (គ.ស១៥២៨) ព្រះបាទអង្គច័ន្ទទី១ ទ្រង់តាំងពញាតាត ងារជាសិទ្ធិភូបាល ជាស្ដេចត្រាញ់ នៅកម្ពុជាក្រោមស្រុកបាសាក់។ ស្ដេចត្រាញ់នេះ បានចាត់របៀបរៀបចំការពារស្រុក មានរបៀប ចែកចេញជាបីក្រុម ដោយទូកនីមួយៗ មានសណ្ឋានរាង ដូចទូកប្រណាំងយើងសព្វថ្ងៃនេះ។ ជាមួយគ្នានេះ ក៏នៅមានជំនឿប្លែកៗ ជាច្រើនទៀត ដែលមានការយល់ផ្សេងៗអំពីបញ្ហាដែលទាក់ទងទៅនឹងពិធីអុំទូកនេះ។

រស្មីកម្ពុជា

ជីវិតមនុស្សរាល់រូបកើតមក ពុំមែនទទួលបានតែភាពសុខសប្បាយ រស់នៅលើគំនរទ្រព្យសម្បត្តិមាសប្រាក់គ្រប់ៗគ្នាទាំងអស់នោះទេ។ អ្នកខ្លះចាប់កំណើតលើត្រកូលគ្រួសារអ្នកមានសម្បត្តិសម្បូរហូរហៀរ ចំណែកអ្នកខ្លះកើតលើគ្រួសារ ដែលស្គាល់តែភាពលំបាកតោកយ៉ាកយ៉ាប់យ៉ឺនស្ទើរតែរៀងរាល់ថ្ងៃ។ ម្ល៉ោះហើយដើម្បីជីវិត ! ពួកគេត្រូវស្ពាយសំពាយលាចាកឆ្ងាយចេញពីគ្រួសារ ដើម្បីស្វែងរកការងារធ្វើរកលុយចិញ្ចឹមជីវិត។ តើមានយុវជន-នារីប៉ុន្មាននាក់ដែលបានលះបង់ការសិក្សា ការរស់នៅជួបជុំគ្រួសាររបស់ខ្លួន ឃ្លាតចាកភូមិស្រុកកំណើតដើម្បីតែការងារនោះ ? តើពួកគេជួបការលំបាកយ៉ាងណាខ្លះក្នុងការរស់នៅ ?

# ចាកចោលភូមិ-ស្រុកកំណើតដើម្បីការងារ



អង្គុយសម្រាកលេងបន្ទាប់ពីនឿយហត់ក្នុងការប្រកបការងារចិញ្ចឹមជីវិត

Photo: S. Philong



Photo: K. Kaghna

បើសិនប្រិយមិត្តទាំងឡាយ មានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។

## តើមូលហេតុអ្វីដែលឱ្យប្រជាជនធ្វើចំណាកស្រុក ?

បើយោងតាមជំរឿនឆ្នាំ១៩៩៨ ប្រជាជនកម្ពុជាចំនួនបីលានបួនសែននាក់ជាជនចំណាកស្រុកនៅក្នុងប្រទេស។ ប្រជាជនខ្មែរជាច្រើនបានផ្លាស់ទីដោយសារហេតុផលទាក់ទងទៅនឹងការងារ ជីវភាព និងគ្រួសារ។ ភាគច្រើននៃពួកគេ គឺរស់នៅក្នុងសភាពក្រីក្រ ហើយត្រូវធ្វើការក្រោមលក្ខខណ្ឌដ៏លំបាក និងរងនូវការកេងប្រវ័ញ្ច។

ស្ត្រីដែលធ្វើចំណាកស្រុក គឺផ្លាស់ទីលំនៅជាមួយក្រុមគ្រួសារ បើទោះបីជា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មានចំនួនស្ត្រីកាន់តែច្រើនឡើងៗ ផ្លាស់ទីមកកាន់ទីប្រជុំជនតែម្នាក់ឯង ស្របពេលដែលឧស្សាហកម្មរោងចក្របង្កើនតម្រូវការពលកម្ម។

អ្នកនាងហ៊ិន ស៊ឿន អាយុ៣៥ឆ្នាំ គឺជាកម្មការិនីកាត់ដេរនៃរោងចក្រកាត់ដេរមិថុនា បានឃ្លាតចាកឆ្ងាយពីកូន និងឪពុកម្តាយប្រមាណ ៤ឆ្នាំមកហើយ។ កត្តាដែលគាត់ត្រូវបែកពីគ្រួសារបែបនេះ ពីព្រោះតែបញ្ហាជីវភាព ទើបត្រូវបង្ខំឱ្យរូបគាត់ឃ្លាតចាកឆ្ងាយបែបនេះ។ អ្នកនាងហ៊ិន ស៊ឿន មានប្រសាសន៍ថា : "ការដែលឱ្យខ្ញុំសម្រេចចិត្ត ចាកចេញពីភូមិកំណើតមករស់នៅឆ្ងាយពីកូនៗនេះ គឺដោយសារតែជីវភាពក្នុងគ្រួសារមានភាពលំបាកខ្លាំងពេក ហើយខ្ញុំមិនដឹងធ្វើអ្វី ក៏សម្រេចចិត្តមកធ្វើការ ក្នុងរោងចក្រនេះតែម្តង"។ ក្នុងមួយខែ អ្នកនាងហ៊ិន ស៊ឿន ទទួលបានប្រាក់បៀវត្សរ៍ ៥៥ដុល្លារ ប៉ុន្តែបើគាត់ធ្វើការលើសម៉ោង គាត់អាចទទួលបាន ពី៨០-១០០ដុល្លារ។ "ខ្ញុំគិតថា នឹងត្រលប់ទៅស្រុកកំណើតវិញ ពីព្រោះការងាររោងចក្រ ក៏មិនអាចឱ្យយើងធ្វើរហូតនោះបានទេ ណាមួយដល់ពេលចាស់ កម្លាំងខ្ញុំនឹងថយចុះជាមិនខាន។ ម្យ៉ាងទៀត ខ្ញុំមានធុរៈនៅផ្ទះ មើលខុសត្រូវពីអនាគតរបស់កូនផងដែរ"។ នេះគឺជាសំដីពោរពេញដោយក្តីព្រួយបារម្ភពីអនាគតខ្លួនឯង និងកូនរបស់អ្នកនាងហ៊ិន ស៊ឿន។

## ចំណាកស្រុកជាកត្តាដែលនាំឱ្យមានការជួញដូរមនុស្ស

តើកត្តាអ្វីខ្លះ នាំឱ្យប្រជាជន ដែលចាកចេញទៅទីក្រុងងាយប្រឈមមុខនឹងគ្រោះថ្នាក់ជួញដូរមនុស្សនោះ ?

មានកម្មករ កម្មការិនីរាប់ពាន់នាក់ កំពុងតែធ្វើការនៅតាមបណ្តារោងចក្រនានា ក្នុងនោះ ប្រមាណជាជាង ៩០% គឺជាស្ត្រី នេះបើតាមរបាយការណ៍ស្តីអំពីនិយោជិករោងចក្រ នៅកម្ពុជាឆ្នាំ២០០៤ របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ កម្មការិនីក្មេងៗ បានចាកចេញពីទីជនបទមកកាន់ទីក្រុងជាមួយនិងក្តីសង្ឃឹមខ្ពស់ថា អាចរកចំណូលបានច្រើន និងអាចលើកស្ទួយជីវភាពខ្លួន និងគ្រួសារ។ ទោះជាយ៉ាងណាក្តី តាមស្ថានភាពជាក់ស្តែងនៅតាមបណ្តារោងចក្រ គឺការងារមានការលំបាកលំបិនខ្លាំង ជាមួយនិងការទទួលបាននូវប្រាក់ខែទាបៗ។

> ### ចំណាកស្រុក គឺជាអ្វី ?
> ជាការផ្លាស់ទីទៀងទាត់ ឬតាមរដូវកាល ដោយចាកចេញពីលំនៅដ្ឋាន ឬសហគមន៍តាមរយៈសេចក្តីសម្រេចចិត្តខ្លួនឯង ឬមានសម្ពាធពីខាងក្រៅ ដើម្បីទៅកាន់កន្លែងថ្មី (ក្នុង ឬក្រៅប្រទេស) ជាទីដែលខ្លួនរំពឹងថា នឹងទទួលបានឱកាសខាងផ្នែកសេដ្ឋកិច្ចប្រសើរជាងមុន ការការពារដ៏ប្រសើរ ឬបរិយាកាសដែលគួរជាទីពេញចិត្តទាំងសង្គម និងជីវភាព។

ម្យ៉ាងទៀត ការរីកលូតលាស់ខាងវិស័យទេសចរណ៍ និងការកំសាន្ត ក៏ទាក់ទាញស្ត្រីធ្វើចំណាកស្រុក ឱ្យមកធ្វើជាស្ត្រីលក់ស្រាបៀរ អ្នករត់តុ ឬអ្នកបម្រើតាមសណ្ឋាគារ-ល-។ គឺកត្តាទាំងនេះដែលធ្វើឱ្យស្ត្រីៗ ងាយប្រឈមទៅនឹងការជួញដូរ។

ទាក់ទងនឹងកង្វល់អស់ទាំងនេះ ក្រសួងកិច្ចការនារីដែលមានលោកជំទាវអ៊ឹង កន្ថាផាវី ជារដ្ឋមន្ត្រីបានកំពុងតែធ្វើការផ្សព្វផ្សាយព័ត៌មានពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព កំពុងតែត្រូវបានផ្តល់ដល់ស្ត្រី និងកុមារដែលងាយរងគ្រោះនៅក្នុងខេត្ត-ក្រុងទាំង២៤ របស់ប្រទេសកម្ពុជា។

យុទ្ធនាការផ្សព្វផ្សាយព័ត៌មាននេះ ក៏មានគោលបំណងផ្តល់ព័ត៌មានទៅដល់ប្រជាពលរដ្ឋទូទៅអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ពីផលលំបាកនៃការជួញដូរមនុស្ស និងព័ត៌មានសំខាន់ៗផ្សេងទៀត ពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ យុទ្ធនាការនេះ ក៏នឹងអនុវត្តសកម្មភាពក្នុងខេត្តចំនួន៥ ក្នុងតំបន់ភូមិភាគឦសាន ដែលមានដូចជា ខេត្តព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។

## ភាពស្ងប់ស្ងាត់នៃភូមិស្រុក

នៅពេលដែលយើងធ្វើដំណើរដល់ភូមិដាច់ស្រយាលនានា ពីទីរួមខេត្ត យើងចាប់ផ្តើមមានអារម្មណ៍ថា ហាក់ដូចជាមានភាពស្ងាត់ជ្រងំ មិនឃើញយុវជនយុវនារី។ "ហ៊ឺយ! ពួកគេទៅធ្វើការនៅទីក្រុងអស់ហើយ"។ នេះគឺជាសំឡេងស្រែករបស់អ្នកស្រីប៊ុន ណយ ចាស់ទុំក្នុងភូមិថ្មី ខេត្តកំពង់ចាម។ អ្នកស្រីបានឱ្យដឹងថា ពួកគេត្រូវចាកចេញពីផ្ទះ គឺដោយសារពួកគេត្រូវទៅធ្វើការផ្សេងៗ ដើម្បីជួយដោះស្រាយនូវបញ្ហាក្នុងគ្រួសាររបស់គេ និងអ្នកខ្លះក៏ត្រូវឪពុកម្តាយបង្ខំឱ្យទៅ។ ពួកគេភាគច្រើនទៅធ្វើការនៅទីក្រុងភ្នំពេញ ធ្វើការងារនៅរោងចក្រ និងធ្វើជាកម្មករសំណង់ជាដើម។

អ្នកស្រីប៊ុន ណយ អាយុ៤៣ឆ្នាំ ព្រួយបារម្ភ ចំពោះយុវជន-នារី ដែលចេញទៅធ្វើការនៅតាមបណ្តាខេត្ត-ក្រុង ឆ្ងាយពីផ្ទះខ្លួន។អ្នកស្រីនិយាយថា : "ខ្ញុំព្រួយបារម្ភណាស់ ព្រោះខ្លាចក្រែងមានជនពាលចាប់ធ្វើបាប និងខ្លាចពួកគេត្រូវបោកយកទៅលក់ផងដែរ"។ អ្នកស្រីបន្តថា : កូនខ្លះមិនទាន់ទាំងគ្រប់អាយុផង គេឱ្យទៅធ្វើការរោងចក្រ ដោយខិតខំបន្ថែមអាយុឱ្យគ្រប់១៨ឆ្នាំ។ ពួកគេពុំងាយនឹងបានមកលេងស្រុកទេ លុះត្រាតែមានពិធីសំខាន់ៗដូចជាមង្គលការ ឬមានអ្នកនៅក្នុងក្រុមគ្រួសារទទួលមរណភាពជាដើម។

កំពុងអង្គុយនៅក្រោមដើមដូងក្បែរមាត់ទន្លេ និងមានអំរែកដាក់ស្លឹកឈូក និងចានឆ្នាំងនៅពីមុខ ចំណែកដៃទាំង២កំពុងមមាញឹកលាងចាននំបញ្ចុកយ៉ាងស្ងៀមស្ងាត់។ អ្នកស្រីម៉ាប់ អាយុ ៣៨ឆ្នាំ បានចាកចេញពីស្រុកកំណើតឃ្លាតឆ្ងាយពីកូន ផ្ទះសំបែងដើម្បីស្វែងរកប្រាក់ផ្គត់ផ្គង់គ្រួសាររបស់គាត់។ គាត់បានមកធ្វើការនៅទីក្រុងភ្នំពេញរយៈពេល៥ឆ្នាំហើយ ជាមួយប្តីរបស់គាត់ដែលធ្វើជាអ្នករត់ម៉ូតូឌុប។ ក្នុងមួយថ្ងៃ គាត់អាចរកចំណូលបានពី៨០០០-១០០០០រៀល។ អ្នកស្រីក៏បានមានប្រសាសន៍ទាំងទឹកមុខក្រៀមក្រំថា : "ទោះបីជាពិបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចតស៊ូបានដែរ ធ្វើយ៉ាងម៉េចបើជីវភាពរបស់យើងមានការខ្វះខាត"។

ជាមួយនេះដែរ អ្នកស្រី ប៊ុន ណយ បានបញ្ជាក់ទៀតដែរថា ដោយសារពួកគេចង់ទៅរកលុយ។ ពួកគេមិនអើពើដល់ការរៀនសូត្រទេ។ ពួកគេគិតថា រៀនល្មមៗ ឱ្យតែចេះអានបាន ហើយគេមិនរំពឹងថា រៀនសូត្រ ធ្វើការងារអ្វីធំដុំទេ។ ...

# ...ដើម្បីប្រាក់ទើបយើងត្រូវចាកចេញទៅទីឆ្ងាយ

### នួន កែវស៊ីថា

ជាង២ឆ្នាំហើយ ដែលលោកនួន កែវស៊ីថា អាយុ២២ឆ្នាំ បានឃ្លាតឆ្ងាយពីភូមិកំណើត ទៅធ្វើការងារនៅប្រទេសកូរ៉េ។ លោកជាកម្មករនៅក្នុងរោងចក្រម្ហូបអាហារ តែលោកអាចទទួលបានកម្រៃជាង ១០០០$ ក្នុង១ខែ។ លោកមានប្រសាសន៍ឱ្យដឹងថា: "ការដែលខ្ញុំចាកចេញទៅនេះដោយសារតែការងារនៅស្រុកខ្មែរមិនអំណោយផល និងប្រាក់ខែតិចតួចបំផុត"។ លោកបានសម្តែងនូវក្តីព្រួយបារម្ភក្រោយពេលលោកត្រូវផុតអណត្តិមកស្រុកកំណើតវិញថា បើលោកត្រលប់មកវិញ ហើយគ្មានជំនាញ ឬចំណេះដឹងអ្វីជ្រៅជ្រះ លោកនឹងគ្មានការងារធ្វើ។ លោកនឹងបន្តនៅទីនោះ បើថៅកែរោងចក្រអនុញ្ញាត។

### បាន សុខមាន

"នៅពេលដែលខ្ញុំមានឱកាសចេញទៅក្រៅ គឺខ្ញុំត្រូវតែចេញ ព្រោះមានការងារធ្វើ និងទទួលបានប្រាក់ខែច្រើនទៀតផង"។ នេះជាសំដីរបស់លោកបាន សុខមាន អាយុ ២៣ឆ្នាំ ដែលបានទៅធ្វើការនៅប្រទេសកូរ៉េ រយៈពេល២ខែមកហើយ។ លោកយល់ថា ការដែលប្រជាជនជាច្រើនចេញពីភូមិស្រុក ដើម្បីរកការងារធ្វើនៅក្រៅ គឺមានមូលហេតុផ្សេងៗគ្នា ដូចជាលក្ខណៈគ្រួសារ និងបុគ្គល តែភាគច្រើនដើម្បីស្វែងរកប្រាក់ចំនូលបន្ថែមផ្គត់ផ្គង់គ្រួសារ។ ដូចលោកជាដើម លោកចាកចេញឆ្ងាយព្រោះស្វែងរកប្រាក់ចំណូលចិញ្ចឹមជីវិតខ្លួនឯង និងគ្រួសារ ដែលលោកសុខចិត្តឈប់រៀនដើម្បីការងារក្រៅប្រទេស។

### លឹម កូណាកា

លោកលឹម កូណាកា អាយុ២៧ឆ្នាំ បានទៅធ្វើការនៅប្រទេសកូរ៉េតាំងពីឆ្នាំ២០០៥។ លោកឱ្យដឹងថា: "ខ្ញុំចង់ផ្លាស់ប្តូរ និងស្វែងរកបទពិសោធន៍ការងារនៅក្រៅប្រទេស តែអ្វីដែលខ្ញុំគិតខុសស្រលះ ព្រោះត្រូវប្រើកម្លាំងច្រើន"។ លោកបានជួបប្រទះនូវផលលំបាកមួយចំនួនដែរ ដូចជាអាហារ អាកាសធាតុដែលមានលក្ខណៈប្លែកពីប្រទេសកម្ពុជា និងការងារមានការលំបាកច្រើនដែរដោយសារលោកត្រូវធ្វើការរយៈពេល៨ម៉ោងពេញ តែលោកទទួលបានប្រាក់បៀវត្សរ៍ច្រើន។ តាមចិត្តរបស់លោក គឺមិនចង់ត្រលប់មកប្រទេសកម្ពុជាវិញទេ ព្រោះបញ្ហាការងារនៅស្រុកខ្មែរពិបាករក ហើយទទួលបានចំណូលតិច។

## បងស្រីសូល: "សម្រាប់ខ្ញុំ ធ្វើការជាមួយអ្នកក្រីក្រ គឺជួយពួកគេឱ្យរីកចម្រើននូវសមត្ថភាពផ្ទាល់ខ្លួនពួកគេ"



Photo: H. Sotheary

បងស្រីសូល នៅក្នុងក្រុមបងស្រីបុត្រីមេត្តាករុណា (វ៉ាំងសង់ ដឺ ប៉ូល) សព្វថ្ងៃបងស្រី និងក្រុមកំពុងធ្វើការជាមួយកម្មករកាត់ដេរចំនួន ៣៥នាក់ និងក្មេងៗ ២៥នាក់។ ក្រុមបងស្រីមានការអាណិតអាសូរដល់កម្មករទាំងនោះ ដោយសារឃើញពួកគេចេញចូលក្នុងរោងចក្រ និងកន្លែងផ្សេងៗទៀត ជួនមានភ្លៀង តែគ្មានអាវភ្លៀងពាក់។ ពួកគេគ្មានម្ហូបឆ្ងាញ់ៗ គ្មានជីវជាតិ ធ្វើការហួសម៉ោង និងទទួលបានប្រាក់ខែតិច។ល។ បងស្រីរិះគិតជួយពួកគេតាំងពីឆ្នាំ២០០៣មក ដល់ឆ្នាំ២០០៦ ទើបចាប់ផ្តើមបង្កើតជាកម្មវិធីជួយពួកគេតែម្តង។

បងស្រីមានការអាណិតអាសូរពួកគេជាពន់ពេក ពេលដែលគាត់បានទៅដល់កន្លែងស្នាក់នៅពួកគេ ឃើញពួកគេរស់ក្នុងបន្ទប់តូច មានមនុស្សច្រើននៅលាយឡំគ្នា មានគ្រែគេងតែមួយ ពេលភ្លៀងខ្លាំងត្រូវទឹកលិច។ បងស្រីសូលមានប្រសាសន៍ថា: "ខ្ញុំគួរបង្រៀនពួកគេឱ្យដឹងពីតម្លៃនៃជីវិត តម្លៃនៃការធ្វើអនាម័យ និងតម្លៃក្នុងពេលអនាគតដែលជាហេតុផលនាំឱ្យខ្ញុំបម្រើដល់ពួកគេដើម្បីឱ្យស្គាល់អំពីតម្លៃនៃអាហារ"។ បងស្រីបានសួរគេតើតម្លៃនៃអនាគតរបស់អ្នកវាយ៉ាងម៉េច? គេថា អត់ដឹងទេ! ពួកគេគិតតែជួយឪពុកម្តាយរបស់ពួកគេតែប៉ុណ្ណោះ។

ក្រុមបងស្រីតែងគិតថា តើបងស្រីគួរជួយពួកគេយ៉ាងដូចម្តេចដើម្បីឱ្យរួចផុតពីភាពវេទនា? តើធ្វើយ៉ាងម៉េចដើម្បីកុំឱ្យពួកគេធ្វើការរោងចក្រយូរពេក និងត្រលប់ទៅកាន់ភូមិកំណើតវិញ ហើយធ្វើការទីនោះតែម្តង!។ បងស្រីសូលបញ្ជាក់ ក្នុងសំឡេងស្រាលៗថា: "សម្រាប់ខ្ញុំ ធ្វើការជាមួយអ្នកក្រីក្រ គឺជួយពួកគេឱ្យរីកចម្រើននូវសមត្ថភាពផ្ទាល់ខ្លួន ចំណេះដឹង និងមានអនាគតល្អ"។ ព្រះជាម្ចាស់ប្រទាននូវបញ្ញាស្មារតី និងភាពប៉ិនប្រសប់។ បើអ្នកអាចឃើញពីភាពប៉ិនប្រសប់បញ្ញាស្មារតីរបស់ពួកគេ អ្នកនឹងឃើញការរីកចម្រើនពួកគេដែរ។ យើងគួរលើកតម្កើងសមត្ថភាពពួកគេ ព្រោះពួកគេជាបុត្រព្រះជាម្ចាស់ និងមានសិទ្ធិដូចអ្នកផ្សេងៗដែរ។ យើងនៅទីនេះព្រោះអ្នកក្រ។ មធ្យោបាយដែលយើងជួយ គឺផ្តល់ក្តីមេត្តាករុណា និងក្តីស្រលាញ់ពីព្រះជាម្ចាស់ ដែលធ្វើឱ្យយើងជួយដល់អ្នកក្រីក្រ។ នេះជាក្តីស្រលាញ់នៃព្រះជាម្ចាស់ដែលជំរុញបងស្រីឱ្យជួយអ្នកក្រីក្រ។

អត្ថបទដោយមុំ គន្ធា និងរ៉ូ បូរ៉ា





ទើបតែប៉ុន្មានឆ្នាំសោះ ព្រះសហគមន៍ចំការទៀងបានបង្កើតនូវមុខមាត់យ៉ាងឆាប់រហ័សក្នុងវិស័យអប់រំ។ លោកបូជាចារ្យអ្លូលីវីយេ ក្រោមការដឹកនាំរបស់លោកអភិបាល បានខិតខំពង្រីកនូវវិទ្យា-ស្ថានអប់រំជាច្រើនសម្រាប់សិស្សានុសិស្សជនបទ។

# វិទ្យាស្ថានថ្មី កាត់បន្ថយភាពក្រីក្រ




Photo: H. Rann

កិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសន្តហ្វ្រង់ស្វ័រ និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ

សិក្ខាសាលាមួយ បានចាប់ផ្តើមប្រារព្ធធ្វើឡើង នៅព្រះស-ហគមន៍ចំការទៀងឋិតក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១៥ តុលា ២០០៦កន្លងទៅនេះ ក្រោមប្រធានបទមួយស្តីអំពី "ការអភិវឌ្ឍន៍កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររង លើមុខជំនាញប្រព័ន្ធកសិកម្ម និងការកែឆ្នៃម្ហូបអាហាររបស់វិទ្យាស្ថានឯកទេសកសិកម្មសន្តហ្វ្រង់ស្វ័រ"។

នាឱកាសដ៏មហោឡារិកនោះដែរ មានការចូលរួមដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមចន្ទ សារុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ ឯកឧត្តមចាន់ ណារ៉េត សកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម សិស្សានុសិស្ស អាជ្ញាធរស្រុកត្រាំកក់ និងគ្រិស្តបរិស័ទប្រមាណជាង ៣០០នាក់។

ជាកិច្ចចាប់ផ្តើមនៃកម្មវិធី លោកបូជាចារ្យអ្លូលីវីយេ ក៏មានប្រសាសន៍ទៅកាន់អង្គសិក្ខាសាលាជាមួយនឹងទឹកមុខស្រស់ស្រាយ អមដោយពាក្យពេចន៍ដ៏មានអត្ថន័យថា: "ខ្ញុំចង់ឱ្យគ្រាប់ពូជមួយគ្រាប់នេះ ក្លាយទៅជាផលផ្លែផ្ការាប់រយដល់បងប្អូននៅក្នុងខេត្តតាកែវ"។ លោកបន្តថា ការបង្កើតនេះគឺដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅតាមជនបទ និងជួយបណ្តុះបណ្តាលធនធានមនុស្ស ក៏ដូចជាបង្កើនគំនិតច្នៃប្រឌិតភាពស្មោះត្រង់ ការព្យាយាម និងសាមគ្គីភាពផងដែរ។

ក្នុងនោះដែរ ឯកឧត្តមចន្ទ សារុន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ក្នុងនាមរដ្ឋាភិបាលកម្ពុជា ជូនចំពោះព្រះសហ-គមន៍កាតូលិក ដែលបានចូលរួមចំណែកលើកកម្ពស់ វិស័យអប់រំនៅកម្ពុជា ជាពិសេស បានជួយកុមារក្រីក្រឱ្យបានចូលរៀនសូត្រនៅតាមជនបទនៅវិទ្យាស្ថានសន្តហ្វ្រង់ស្វ័រនេះ។ ឆ្លៀតឱកាសនោះដែរ លោកអភិបាលអេមីល ដេតម្ប ក៏បានរៀបរាប់ពីកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានបច្ចេកវិទ្យាសន្តហ្វ្រង់ស្វ័រ និងសកលវិទ្យាល័យភូមិន្ទភ្នំពេញកសិកម្ម ថាគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលមិនអាចបំភ្លេចបាន។

កសិករសាន សឹម និយាយថា: "ខ្ញុំរីករាយណាស់ ដោយកូនរបស់ខ្ញុំម្នាក់បានសិក្សានៅក្នុងវិទ្យាស្ថាននេះ ដែលខ្ញុំយល់ថាតាំងពីដើមមកមិនដែលមានវិទ្យាស្ថាននៅស្រុកស្រែទេ"។ ចំណែកយុវសិស្សនន សន មកពីវិទ្យាល័យព្រៃធប់ កំពុងតែរៀបចំតុវេទិកាសិក្ខាសាលា និយាយដែរថា វិទ្យាស្ថាននេះគឺមានសារៈសំខាន់ណាស់ ដែលផ្តល់ឱកាសដល់កូនកសិករ ឱ្យបានសិក្សា ពិសេសពេលបញ្ចប់ការសិក្សា នៅវិទ្យាស្ថាននេះ និស្សិតអាចសិក្សាបន្តនៅភ្នំពេញ ឆ្នាំទី៣តែម្តង។

ក្នុងទឹកមុខញញឹមប្រកបដោយភាពសប្បាយរីករាយ លោកគ្រូអ្លូង យុំ សាស្ត្រាចារ្យបង្រៀន នៅវិទ្យាស្ថាននេះ បានឱ្យដឹងថា លោកមានចិត្តសប្បាយរីករាយ និងមានមោទនភាពណាស់ដោយលោកបានក្លាយខ្លួនជាសាស្ត្រាចារ្យនៅទីនេះ។ លោកបន្ថែមទៀតថា សិស្សដែលប្រលងជាប់បាក់ឌុបហើយមិនបាច់ទៅណាឆ្ងាយ ឬក៏បន្តការសិក្សានៅភ្នំពេញទេ គឺពួកគេមានវិទ្យាស្ថានសិក្សា នៅទីនេះតែម្តង។ និស្សិត តែកាលណាមានកន្លែងសិក្សានៅជិតផ្ទះ ពួកគេមិនអាចលះបង់ការសិក្សាទេ។ ពួកគេនឹងស្វះស្វែងមកសិក្សាដោយរីករាយ។

វិទ្យាស្ថានឯកទេសកសិកម្មសន្តហ្វ្រង់ស្វ័រ ក៏បានសហការជាមួយសកលវិទ្យាល័យភូមិន្ទកសិកម្ម និងទទួលនិស្សិត ដំបូងចំនួន ៤៥នាក់ ដែលមាននិស្សិត នៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ ១៣នាក់ និងនិស្សិតមកពីសាលាផ្សេងៗ ៣២នាក់ ដែលការចូលរៀនត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកានេះ។

ហ៊ិន រ៉ាន់

### សិក្ខាសាលា

ត្រូវបានរៀបចំ និងដឹកនាំដោយអ្នកមានបទពិសោធន៍នៅសកលវិទ្យាល័យភូមិភ្នំពេញកសិកម្ម ហើយគឺជាឱកាសមួយដ៏ល្អប្រសើរបំផុតក្នុងការកំណត់ទិសដៅចំពោះវិទ្យាស្ថានបច្ចេកវិទ្យាសន្តហ្វ្រង់ស្វ័រក្នុងការមានទំនាក់ទំនងដោយផ្ទាល់នៅតាមជនបទ។ សិស្សានុសិស្សនឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលនូវចំណេះដឹងថ្មីៗ ទាក់ទងនឹងបច្ចេកទេសចាប់តាំងពីការរៀនលើកដំបូងនេះតទៅ។ នៅឆ្នាំ២០០៨ខាងមុខនេះវិទ្យាស្ថានបច្ចេកវិទ្យាសន្តហ្វ្រង់ស្វ័រក៏នឹងបង្កើតកម្មវិធីបណ្តុះបណ្តាលមួយ ដែលមានឈ្មោះថា: "កម្មវិធីកែច្នៃអាហារកសិកម្ម"។

# គ្រិស្តបរិស័ទយកគំរូតាមមរណសាក្សី

**កាលណានរណាម្នាក់ធ្វើអ្វីមួយដែលជាគំរូនៃមនុស្សទូទៅ និងផ្តល់ជាប្រយោជន៍សម្រាប់ប្រទេសជាតិ ឬសម្រាប់អ្នកដែលខ្លួនស្រលាញ់ ប្រាកដណាស់ថា មនុស្សជំនាន់ក្រោយនឹងតម្កល់អ្នកនោះធ្វើជាគំរូ ហើយគេនាំគ្នាគោរព និងធ្វើតាមទង្វើរបស់គាត់។**


លោកបូជាចារ្យ ទម្លាប់ សុផល ឆ្លើយសំនួរទាក់ទងនឹងព្រះសហគមន៍

Photo: L. Sovanna

**សំណួរ : តើមរណសាក្សីជានរណា ?**

**លោកបូជាចារ្យទម្លាប់ សុផល :** ពាក្យមរណសាក្សី មកពីពាក្យមរណៈ បូកនិងសាក្សី ដែលជាអ្នកស៊ូស្លាប់ព្រោះតែជំនឿ និងចង់បង្ហាញពីជំនឿដើម្បីធ្វើជាបន្ទាល់សាក្សីនៅក្នុងជីវិតរបស់ខ្លួន។ ចំពោះគ្រិស្តសាសនា ពាក្យមរណសាក្សីប្រើពិសេសសម្រាប់សំដៅលើបុរស ឬក៏ស្ត្រីដែលបង្ហាញ ពីជំនឿរបស់ខ្លួនលើព្រះយេស៊ូគ្រិស្តរហូតដល់ហ៊ានប្តូរជីវិត។ យើងអាចប្រើពាក្យមរណភក្តី ជាមនុស្សហ៊ានបូជាជីវិត ព្រោះតែមានភក្តីភាពចំពោះព្រះជាម្ចាស់ និងស្រលាញ់ព្រះអង្គដូចជាព្រះយេស៊ូដែរ ដោយស្រឡាញ់អស់ពីចិត្តគំនិតស្មារតី កម្លាំងកាយចិត្ត និងស្មោះស្ម័គ្រជាមួយព្រះជាម្ចាស់ឱ្យដល់ទីបំផុត។ នៅក្នុងព្រះសហគមន៍កាតូលិកពាក្យមរណសាក្សីបានទទួលបន្ថែមអត្ថន័យ គឺអស់អ្នកធ្វើសាក្សី ឬអស់អ្នកដែលជឿ ធ្វើបន្ទាល់បញ្ជាក់យ៉ាងឱឡារិកថា ព្រះយេស៊ូគ្រិស្តត្រូវបានព្រះបិតាប្រោស ឱ្យមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។ នៅឆ្នាំ៦៤ នៃគ្រិស្តសករាជ យើងចាប់ផ្តើមឃើញមានមរណសាក្សីដើមដំបូងនៅទីក្រុងរ៉ូម បន្ទាប់មកចូលសតវត្សរ៍ ទី៤ ក៏មានសន្តីអាញ៉េស ដែលទើបតែមានអាយុ ១២ឆ្នាំប៉ុណ្ណោះ នាងហ៊ានប្តូរជីវិតព្រោះតែជំនឿ។ ចំណែកនៅអាស៊ី នៅប្រទេសជប៉ុន ឆ្នាំ១៥៩៧ លោកប៉ូលមិគី រួមនិងសហជីវិនមួយក្រុមដូចជាគ្រូបង្រៀន អ្នកបកប្រែភាសា គ្រូពេទ្យ និងក្មេងៗ ក៏ត្រូវព្រះចៅអធិរាជបង្ខំឱ្យលះបង់ជំនឿ តែបងប្អូនទាំងនោះបានថ្វាយជីវិតទៅព្រះជាម្ចាស់។

**សំណួរ : តើយើងគួរគោរពមរណសាក្សីបែបណា ?**

**លោកបូជាចារ្យទម្លាប់ សុផល :** ដំបូងបង្អស់យើងឃើញនៅក្នុងសៀវភៅពិធីបុណ្យគោរពសន្តបុគ្គលប្រចាំឆ្នាំ។ ព្រះសហគមន៍កាតូលិក បានរៀបរៀងនឹករំលឹកមរណសាក្សីក្នុងបញ្ជីប្រតិទិនប្រចាំឆ្នាំរបស់សន្តបុគ្គល។ ត្រង់នេះសឱ្យឃើញថា ព្រះសហគមន៍កាតូលិកបានលើកតម្លៃ អស់មរណសាក្សីដោយទទួលស្គាល់ថា បងប្អូនទាំងនោះជាសន្តបុគ្គល នៅក្នុងចំណោមសន្តបុគ្គលទាំងឡាយ។ ព្រះសហគមន៍ មានបំណងដាស់តឿនឱ្យគ្រិស្តបរិស័ទ មើលគំរូរបស់មរណសាក្សី ដែលធ្វើជាបន្ទាល់បញ្ជាក់យ៉ាងឱឡារិកអំពីព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងដោយតម្លៃក្នុងជីវិតរបស់ខ្លួន ដើម្បីពេលជួបឧបសគ្គ ឬក៏ទុក្ខលំបាកនានាគ្រិស្តបរិស័ទ នៅតែស្ម័គ្រចិត្តផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ដូចបងប្អូនមរណសាក្សីទាំងអស់នោះដែរ។ ក្រៅពីនេះ មានបងប្អូនខ្លះបានជ្រើសរើសយកឈ្មោះរបស់មរណសាក្សី មកធ្វើជាឧបការីនៅពេលខ្លួនជ្រមុជទឹក គឺក្នុងបំណងសូមឱ្យមរណសាក្សីដែលបានទៅរួមរស់ជាមួយព្រះជាម្ចាស់រួចហើយនោះ តាមថែរក្សា និងអង្វរព្រះជាអម្ចាស់ឱ្យខ្លួន ឱ្យតាមថែទាំការពារជាពិសេសនៅពេលជួបឧបសគ្គនឹងជំនឿ ព្រមទាំងអង្វរសូមឱ្យមរណសាក្សីទាំងនោះការពារខ្លួនកុំឱ្យបាត់បង់ជំនឿទៀតដែរ។ ម្យ៉ាងទៀត ក៏នៅមានព្រះវិហារខ្លះគ្រិស្តសាសនាបានជ្រើសរើសនាមសន្តមរណសាក្សី មកធ្វើជាឧបការី និងដាក់ឈ្មោះឱ្យព្រះសហគមន៍របស់ខ្លួនដើម្បីឱ្យមរណសាក្សីទាំងនេះ ជួយដំណើរជីវិតរបស់គេ រួមរស់ជាមួយព្រះយេស៊ូរហូតដល់ទីបំផុត ទោះបីជាជួបឧបសគ្គយ៉ាងណាក៏ដោយ។

មុំ គន្ធា

## ស្រាយចម្ងល់

ប្រសិនបើប្រិយមិត្តអ្នកអាន អ្នកនាំសារ មានចម្ងល់ ឬមានសំណួរទាក់ទងទៅនឹងព្រះសហគមន៍កាតូលិក ក៏ដូចជារឿងរ៉ាវ ដែលប្រិយមិត្តមិនទាន់យល់ច្បាស់អំពីព្រះជាម្ចាស់។ ប្រិយមិត្តអាចសរសេរជាសំណួរមកការិយាល័យអ្នកនាំសារ តាមរយៈលោកបូជាចារ្យនៅជិតបំផុត ឬទូរស័ព្ទលេខ : ០១៦ ៣២៦ ៧៣៧ /០១២ ៣៣៨ ៩៨៥។ យើងខ្ញុំនឹងបកស្រាយជូនប្រិយមិត្តតាមរយៈការអញ្ជើញលោកបូជាចារ្យនានានៃភូមិភាគទាំងបី។





# សណ្តែកដីសម្បូរជាតិប្រេង

**បើនិយាយអំពីសណ្តែកដី គ្រាប់របស់វាមានរសជាតិឆ្ងាញ់ ដែលប្រជាជនលើពិភពលោកនិយមបរិភោគ។ វាជាដំណាំសម្បូរជាតិប្រេង ប្រូតេអ៊ីន និងវីតាមីនផ្សេងៗ។ ប្រេងសណ្តែកដីផ្តល់ផលប្រយោជន៍ច្រើន ដូចជាអាចបរិភោគ ធ្វើប៊ឺ អាហារកំប៉ុង សាប៊ូ ឬប្រេងសម្រាប់គ្រឿងយន្ត-ល-។**


លោកលឹម សុខាភក្តី

តាមប្រសាសន៍របស់លោកលឹម សុខាភក្តី និស្សិតសិក្សាថ្នាក់បណ្ឌិតកសិកម្មនៅប្រទេសវៀតណាម និងកំពុងស្រាវជ្រាវពីប្រព័ន្ធកសិកម្មនៅកម្ពុជា បានរៀបរាប់អំពីដំណាំសណ្តែកដី និងបច្ចេកទេសដាំដុះវាថា :

ដំណាំសណ្តែកដីមិនត្រូវការកម្តៅថ្ងៃក្តៅពេក ឬត្រជាក់ពេកទេ។ សីតុណ្ហភាពសមរម្យ គឺពី២៥ ទៅ៣២ អង្សារសេ។ វាត្រូវការពន្លឺជាសំខាន់សម្រាប់លូតលាស់។សណ្តែកដីត្រូវការទឹក ជាពិសេសនៅវគ្គចាប់ផ្តើមចេញផ្ការហូតដល់បង្កើតផ្លែ។ វាត្រូវការសំណើមដីមិនឱ្យក្រោម៥០ភាគរយទេ និងមិនឱ្យលើសពី ៩០ភាគរយដែរ ដែលអាចឱ្យមើមរលួយ។

ដើម្បីដាំដុះសណ្តែកដីឱ្យបានទិន្នផលខ្ពស់ យើងត្រូវតែជ្រើសរើសគ្រាប់សណ្តែកដីពូជនូវគ្រាប់ណា ដែលមិនស្វិត មិនបែកពុំពេញលក្ខណៈ ដុះផ្សិត ឬមួយខូតខាតដោយសារសត្វល្អិតបំផ្លាញ។ មុននឹងដាំ គេត្រូវយកគ្រាប់សណ្តែកទៅហាលថ្ងៃតែកុំឱ្យក្តៅពេក ហាលក្នុងរយៈពេលពី៦ ទៅ៨ម៉ោង ដើម្បីជួយបង្កើនកម្លាំងក្នុងការដុះ។ ពេលវេលាដាំដុះ គឺប្រែប្រួលទៅតាមរយៈពេលលូតលាស់របស់ពូជនីមួយៗ និងទៅតាមទឹកភ្លៀង។ ជាទូទៅ គេកំណត់ពេលដាំ ដោយលៃយ៉ាងណាឱ្យពេលចេញផ្កា មានទឹកភ្លៀងគ្រប់គ្រាន់ និងពេលសណ្តែកដីចាស់ ត្រូវនឹងពេលចាប់ផ្តើម ឬចំរដូវស្ងួតតែម្តង។

ដំណាំសណ្តែកដីត្រូវការដីជ្រៅធូរ ដូច្នេះយើងត្រូវភ្ជួរឱ្យបានជ្រៅល្មម គឺជម្រៅពី ២០ ទៅ២៥ស.ម។ យើងក៏ត្រូវហាលដីឱ្យឆ្អិនល្អ កុំឱ្យជាំទឹក ពិតមែនតែសណ្តែកដី ត្រូវការទឹកជាចាំបាច់ ប៉ុន្តែវាក៏មិនអាចដុះលូតលាស់បានល្អនៅលើដីជាំទឹកដែរ។ ចំពោះការដាក់គ្រាប់ដាំ គឺយើងគួរដាក់ ១ ឬ២គ្រាប់ក្នុងជម្រៅ ៣ស.ម នោះយើងនឹងចំណេញពូជច្រើន។

សម្រាប់សណ្តែកដី យើងចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការថែទាំ។ យើងត្រូវធ្វើស្មៅយ៉ាងតិចឱ្យបាន ២ដង បើសិនមានភ្លៀងធ្លាក់ខ្លាំង យើងអាចធ្វើពី៣ ទៅ៤ដង។ លើកទីមួយ គឺចាប់ផ្តើមក្រោយពេលដាំ ១៥ថ្ងៃ។ លើកទី២ គឺនៅពេលមុនចេញផ្កា៣០ ឬ៤០ថ្ងៃក្រោយពីការដាំ។ ប៉ុន្តែការងារចាំបាច់សម្រាប់សណ្តែកដី គឺការជ្រំដី និងពូនគល់។ ការជ្រំដីនេះ គឺត្រូវអនុវត្ត ១ ឬ២ដង មុនពេលចេញផ្កា ឬក៏ពេលចាប់ផ្តើមចេញផ្កា ដើម្បីឱ្យពន្លកផ្លែចាក់ចូលដីបានស្រួល។

សត្រូវដែលចាំបំផ្លាញដំណាំសណ្តែកដី គឺមានពពួក មេរោគផ្សិតផ្សេងៗ។ ចំណែកពួកសត្វល្អិតក៏មានច្រើនប្រភេទ ដូចជា ដង្កូវពណ៌ប្រផេះ ស្រមោច ឬក៏សត្វចង្រិត ដែលតែងតែស៊ីពន្លកសណ្តែកដី ដែលធ្វើឱ្យដំណាំនេះពុំអាចលូតលាស់ទៅមុខបាន។ ដូច្នេះដើម្បីបង្ការជំងឺពីមេរោគផ្សិត យើងត្រូវតែធ្វើការសម្រាំងជ្រើសរើស តែគ្រាប់ពូជណា ដែលល្អ និងត្រូវបានរក្សាទុកឱ្យបានយ៉ាងល្អ ជាពិសេសនោះ យើងអាចប្រើថ្នាំធម្មជាតិសម្លាប់ផ្សិត និងសត្វល្អិតផងដែរ។ ចំណែកឯថ្នាំគីមី យើងអាចប្រើ DDT ក៏បាន បើចៀសប្រើមិនបាន។

ផាត សំភី

## កន្លែងសិក្សា

ប្រសិនបើលោកអ្នកចង់សិក្សាអំពីរបៀប ឬបច្ចេកទេសនៃការដាំដំណាំគ្រប់ប្រភេទគឺមាននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) ឬអាចអញ្ជើញបុគ្គលិករបស់សេដាកទៅបង្រៀនដល់ទីកន្លែងតែម្តងដោយពិភាក្សាតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០១២ ៣២៥៧១០។


ដើម្បីឱ្យសណ្តែកទទួលបានទិន្នផលខ្ពស់ យើងត្រូវឧស្សាហ៍ធ្វើការជម្រះស្មៅ

Photos: DR

## តើរូបខាងក្រោមនេះគឺជារូបអ្វី? សូមគូសភ្ជាប់ពីចំនុចលេខរៀងទី១ រហូតដល់លេខ៤១ ប្រិយមិត្តនឹងដឹងជាក់ជាមិនខាន។






# អ្នកចាត់ចែងថវិកា

ការគ្រប់គ្រងថវិកាជាការងារមួយកំពុងពេញនិយម ពីព្រោះការងារនេះមិនសូវជាប្រើកម្លាំងកាយដូចជាការងារដទៃទេ ប៉ុន្តែវាត្រូវការគំនិតគិតច្រើន។ តើការងារនេះមានសកម្មភាពយ៉ាងណាដែរទៅ?


Photo: P. Samphy

នេះគឺជាការងារមួយដែលទាមទារនូវភាពម៉ត់ចត់ ពិនិត្យពិច័យ

អ្នកចាត់ចែងថវិកា ឬក៏អ្នកគ្រប់គ្រងការិយាល័យហិរញ្ញវត្ថុ ដែលភាគច្រើនគេនិយមហៅជាភាសាអង់គ្លេសថា: Office Finance ឬ Office Manager។ អ្នកធ្វើការងារនេះគឺមានភារកិច្ចសម្រាប់ឆែកបញ្ជីរបស់គេ ព្រោះបុគ្គលិកគេត្រូវការលុយ ពេលគេមកយកលុយ អ្នកចាត់ចែងថវិកាចារក្រដាសឱ្យគេដើម្បីឱ្យគេទៅយកលុយពីម្នាក់ទៀត ដែលគេហៅថាគណនេយ្យករ។ អ្នកនាងស្រួយ ចន្ទុល ដែលជាអ្នកចាត់ចែងថវិកា នៅអង្គការម៉ារីណុល បានមានប្រសាសន៍ថា: "ដើម្បីឱ្យការងាររបស់យើងមានភាពរលូន យើងត្រូវតែធ្វើឱ្យបានម៉ត់ចត់ គឺដូចជារបាយការណ៍លុយ យើងចេញរាល់ថ្ងៃ យើងត្រូវឆែករាល់ថ្ងៃ បើសិនជាមានកំហុស យើងត្រូវបញ្ជូនទៅឱ្យគេវិញជាបន្ទាន់"។ អ្នកនាងបន្តថា យើងបញ្ជូនទៅឱ្យគេដើម្បីឱ្យគេកែ។ យើងត្រូវការនូវភាពត្រឹមត្រូវ ពីព្រោះតែគណនេយ្យគ្រប់កន្លែងទាំងអស់ត្រូវមានអ្នកមកត្រួតពិនិត្យ ដែលគេហៅថាមកធ្វើAudite (ធ្វើសវនកម្ម ឬត្រួតពិនិត្យ) ប្រសិនគណនេយ្យយើង ត្រូវគេពិនិត្យឃើញថា មានកំហុស ឬមានបញ្ហានោះ គេនឹងស្ដីបន្ទោសដល់យើង ឬកន្លែងរបស់យើងតែម្ដង។ បើសិនជាការចំណាយធំគឺត្រូវតែឆ្លងកាត់ការអនុញ្ញាតពីប្រធានធំរបស់យើង។ យើងគ្រាន់តែជាអ្នកគ្រប់គ្រងការចំណាយក្នុងកម្រិតមួយដែលគេអនុញ្ញាតប៉ុណ្ណោះ។ អ្នកនាងចន្ទុល បានបន្ថែមទៀតដែរថា ការងារនេះមានការពិបាកត្រង់ថា ភាសាយើងមិនទាន់ចេះទាំងអស់ ជាពិសេសពាក្យបច្ចេកទេសផ្នែកគណនេយ្យ។ ភាសាបរទេសគឺសំខាន់ណាស់សម្រាប់ជំនាញរបស់យើង។ យើងត្រូវផ្ដោតការយកចិត្តទុកដាក់ចំពោះការរៀនភាសាបរទេស តួយ៉ាងដូចជា បើចំណាយទៅលើអ្វីមួយ ក៏ត្រូវសរសេរជាភាសាបរទេសទាំងអស់នៅលើរបាយការណ៍ ពុំមែនភាសាខ្មែរទេ។ ដូច្នេះយើងត្រូវយកចិត្តទុកដាក់ចំពោះភាសាផងដែរ។

សម្រាប់ប្រាក់បៀវត្សរ៍ គេគិតទៅតាមកម្រិតសិក្សា បើសិនយើងគ្មានសញ្ញាប័ត្រ គេគិតឱ្យយើងតែ ១២០ដុល្លារ ក្នុង១ខែ តែបើយើងមានបរិញ្ញាប័ត្រ និងបទពិសោធន៍នោះ យើងទទួលបាន១៥០ដុល្លារ ឬលើសពីនេះ។ ជួនកាល យើងអាចចរចាជាមួយប្រធានដើម្បីឱ្យសមនឹងសមត្ថភាពយើង។

មុំ គន្ធា និងផាត សំភី

### សាលារៀន

ជំនាញគណនេយ្យមានបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាជាច្រើននៅទីក្រុងភ្នំពេញ ដោយអាហារូបករណ៍ ឬបង់ថ្លៃ។ នៅវិទ្យាស្ថានវ៉ាន់ដាគណនេយ្យ អគារលេខ២១៦-២១៨ មហាវិថីម៉ៅសេទុង ទូរស័ព្ទ: ០២៣ ២១៣ ៥៦៣។ សកលវិទ្យាល័យជាតិគ្រប់គ្រង ទូរស័ព្ទ: ០២៣ ៤២៨១២០ ។ សកលវិទ្យាល័យន័រតុន ផ្លូវ១១៨ ទូរស័ព្ទ: ០២៣ ៩៨២១៧៧។

សុខភាព

# ភ្នែកឡើងបាយ

ភ្នែកមានតម្លៃណាស់សម្រាប់មនុស្ស។ ប៉ុន្តែភ្នែកនេះក៏តែងតែជៀសមិនផុតពីជំងឺនានាដែលយាយីរំខានដែលអាចធ្វើឱ្យវាងងឹតខ្វាក់ជារៀយៗ ជាពិសេសជំងឺភ្នែកឡើងបាយ។

តាមប្រសាសន៍របស់លោកសួរ ចំរើន ជាវេជ្ជបណ្ឌិតផ្នែកចក្ខុរោគសាស្ត្រនៃមន្ទីរពេទ្យកាល់ម៉ែត បានប្រាប់ឱ្យដឹងថា នៅប្រទេសកម្ពុជា គេសង្កេតឃើញប្រជាជនភាគច្រើនកើតជំងឺឡើងបាយភ្នែក។ ជំងឺនេះ បានបង្ហាញឱ្យឃើញនូវការឡើងស្រអាប់នៃកែវភ្នែកបន្តិចម្ដងៗ រហូតដល់ងងឹតតែម្ដង។ មូលហេតុនៃជំងឺនេះ មានដូចជា វាកើតឡើងដោយឯកឯង និងដោយធម្មជាតិ នៅពេលដែលមនុស្សយើងមានវ័យចាស់ជរា។ ទីពីរ វាកើតឡើងនៅលើមនុស្សវ័យក្មេង ដោយសាររបួសភ្នែក មានជាអាទិ៍ដោយសារគ្រោះថ្នាក់ចរាចរណ៍ ឬក៏គ្រោះថ្នាក់ក្នុងការងារជាដើម។ ទីបី គឺវាកើតឡើងបណ្ដាលមកពីជំងឺនានា ដែលធ្វើឱ្យឡើងបាយភ្នែកដែរ ដូចជាជំងឺឈឺសន្លាក់ ទឹកនោមផ្អែម លើសឈាម-ល-។ ហើយវាក៏មានករណីខ្លះ ដែលភ្នែកឡើងបាយកើតមានពីកំណើតផងដែរ។ ដើម្បីព្យាបាលជំងឺភ្នែកឡើងបាយ គឺទាល់តែធ្វើការវះកាត់ដែលមានតែវេជ្ជបណ្ឌិតជំនាញទេដែលអាចធ្វើបាន។ លោកវេជ្ជបណ្ឌិត សួរ ចំរើន បានសង្កត់ធ្ងន់ថា ប្រសិនយើងដឹងខ្លួនថា មានការស្រវាំងភ្នែក ឬឡើងបាយភ្នែក យើងគួរទៅមន្ទីរពេទ្យ ជាបន្ទាន់ ដើម្បីឱ្យវេជ្ជបណ្ឌិតឯកទេសពិនិត្យព្យាបាល បើបានរឹតតែឆាប់រឹតតែល្អ។ យើងត្រូវជៀសវាងការប្រើថ្នាំផ្ដេសផ្ដាស ស្ដោះផ្លុំដាក់ភ្នែក ឬប្រើឱសថបុរាណដាក់ចូលក្នុងភ្នែកដែលនាំឱ្យមានគ្រោះថ្នាក់ដល់ភ្នែក។ ជំងឺភ្នែកឡើងបាយមនុស្សចាស់ ពុំមែនជាជំងឺឆ្លងទេ ហើយមិនអាចការពារបានដែរ ព្រោះវាកើតឯកឯង។ តែជំងឺភ្នែកឡើងបាយមួយចំនួនតូច ដែលបណ្ដាលមកពីជំងឺផ្សេងៗ និងពីរបួស យើងអាចបង្ការបានដោយការថែទាំសុខភាព ដូចជាហាត់ប្រាណ មិនជក់បារី មិនពិសារស្រា បរិភោគអាហារមានប្រយោជន៍ និងចេះការពារខ្លួនកុំឱ្យមានគ្រោះថ្នាក់។

ផាត សំភី


Photo: P. Samphy

លោកវេជ្ជបណ្ឌិតសួរ ចំរើន ប្រចាំនៅមន្ទីរពេទ្យកាល់ម៉ែត

### កន្លែងព្យាបាល

បើប្រិយមិត្តមានជំងឺភ្នែក អាចទៅព្យាបាលជាមួយលោកវេជ្ជបណ្ឌិតសួរ ចំរើន ផ្ទះ ២៦៣ ផ្លូវ ១០៧ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា ក្រុងភ្នំពេញ។ ទូរស័ព្ទ: ០១២ ៨៥៥ ១៦០។

# លោកអូលីវីយេ: "អ្វីដែលយើងធ្វើ គឺដើម្បីឱ្យយុវជន-នារីរីកចម្រើន"



Photo: L. Sovanna

លោកបូជាចារ្យ អូលីវីយេ ផិតហស្តេ

**លោកបូជាចារ្យបានសាងនូវសមិទ្ធផលជាច្រើនដូចជាវិទ្យាល័យសន្តហ្វ្រង់ស្វ័រ ចំការទៀង មណ្ឌលតម្បាញសូត្រ និងមណ្ឌលថែរក្សាអ្នកជំងឺអេដស៍នៅភ្នំវល្លិជាដើម។**

លោកបូជាចារ្យអូលីវីយេ ដែលជាជនជាតិបារាំង និងមានអាយុ៣៦ឆ្នាំ បានមករស់នៅក្នុងប្រទេសកម្ពុជា អស់រយៈពេល៨ឆ្នាំមកហើយ។ នេះគឺជាប្រទេស ដែលលោកបានកសាងនូវស្នាដៃជាច្រើន ទាក់ទងទៅនឹងវិស័យអប់រំ និងភាពសប្បុរសធម៌ ដូចជាវិទ្យាល័យសន្តហ្វ្រង់ស្វ័រ នៃភូមិចំការទៀង ឃុំគុសស្រុកត្រាំកក់ ខេត្តតាកែវ មណ្ឌលតម្បាញសូត្រ មណ្ឌលរក្សាអ្នកជំងឺអេដស៍នៅភ្នំវល្លិ ខេត្តកំពត និងមណ្ឌលយុវជននៅភ្នំពេញផងដែរ។

លោកបូជាចារ្យរូបនេះ បានជួយដល់យុវជន-នារីឱ្យពួកគេមានឱកាស បានបន្តការសិក្សាតទៅមុខទៀត ជាពិសេសយុវជននៅខេត្តតាកែវ និងកំពត ដែលលោកចាត់ចែងតាំងពីឆ្នាំ២០០២។

លោកឪពុកអូលីវីយេ មានប្រសាសន៍ទៀតថា : "អ្វីដែលយើងខិតខំធ្វើរាល់ថ្ងៃ គឺដើម្បីឱ្យយុវជន-នារី មានការរីកចម្រើនទាំងកម្លាំងកាយ ប្រាជ្ញា និងវិញ្ញាណ"។ លោកក៏បន្តថា: នៅក្នុងអំឡុងឆ្នាំ២០០២នោះដែរ មានយុវជនប្រលងជាប់បាក់ឌុបតែ១៥-២០%ប៉ុណ្ណោះ ហើយភាគច្រើនមិនមានសមត្ថភាពបន្តការសិក្សានៅតាមមហាវិទ្យាល័យនានានៅភ្នំពេញឡើយ ដោយសារតែអត់លុយ។ ដោយមើលឃើញដូចនេះហើយ លោកបង្កើតនូវសាលារៀនគួរពេលយប់ ដែលមានបង្រៀនគ្រប់មុខវិជ្ជា និងមានសិស្សរៀនជាង៨០នាក់។

"តាំងតែពីឆ្នាំ២០០៣ យើងបានបង្កើតនូវសាលាសន្តហ្វ្រង់ស្វ័រ ដោយខ្ញុំប្រកាន់យកពាក្យស្លោកថា ការទទួលខុសត្រូវ សាមគ្គីភាព និងមានចិត្តស្មោះស្ម័គ្រ ដែលនេះជាការដាស់តឿនមួយ សម្រាប់ឱ្យសិស្សចេះផ្តល់សេចក្តីស្រឡាញ់ និងទុកចិត្តគ្នាទៅវិញទៅមក។ បើយើងចេះទទួលខុសត្រូវចំពោះកិច្ចការតូចតាច នោះ យើងក៏អាចទទួលខុសត្រូវចំពោះកិច្ចការធំបានដែរ"។ នេះជាសំដីយ៉ាងម៉ឺងម៉ាត់របស់ លោកបូជាចារ្យអូលីវីយេ។ តាមពិតគ្រប់កិច្ចការដែលលោកធ្វើ លោកតែងតែសង្ឃឹមផងដែរថា នឹងជួយយុវជនឱ្យមានការរីកចម្រើន ដែលធ្វើឱ្យពួកគេអាច ជួយដល់ក្រុមគ្រួសាររបស់ខ្លួនបាន។ នេះគឺជាមោទនភាពនៅក្នុងជីវិតរបស់លោក។ លោកបានបន្ថែមថា សម្រាប់ការសិក្សាអប់រំដែលលោកផ្តល់ឱ្យពួកគេនោះ លោកសង្កេតឃើញថា មានសិស្សមួយចំនួន ក៏យកចិត្តទុកដាក់រៀន និងមានការងារធ្វើជួយដល់គ្រួសារ តែមួយចំនួនទៀត គឺចាំតែយើងជួយជំរុញរហូត។

"ខ្ញុំមានអំណរសប្បាយ ដោយបានបម្រើព្រះស-ហគមន៍កាតូលិក ហើយខ្ញុំនឹងនៅតែបន្តជួយដល់ព្រះសហគមន៍ជានិច្ច ជាពិសេសគឺទាក់ទងនឹងការអប់រំយុវជនតែម្តង"។ នេះគឺជាទឹកចិត្ត ដ៏មុតមាំរបស់លោកបូជាចារ្យអូលីវីយេ។

សព្វថ្ងៃនេះ សាលាសន្តហ្វ្រង់ស្វ័រ មានសិស្សចំនួន ១០៧នាក់ ហើយរៀងរាល់ឆ្នាំ សាលាជ្រើសរើសសិស្សចំនួន ៣៦នាក់ប៉ុណ្ណោះ ពីព្រោះសិស្សដែលត្រូវជ្រើសរើស គឺជាអ្នកដែលមកពីគ្រួសារក្រីក្រ ហើយពួកគេចង់រៀននូវជំនាញយ៉ាងពិតប្រាកដ។ ខែវិច្ឆិកា ឆ្នាំ២០០៦នេះ នៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ មានបើកវិទ្យាស្ថានកសិកម្ម ដោយសហការជាមួយសកលវិទ្យាល័យកសិកម្មភ្នំពេញ។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍សំខាន់!

- ពីថ្ងៃទី១ ដល់ទី១០ វិច្ឆិកា : មានពិធីសំណាក់ធម៌របស់ក្រុមបព្វជិតសហជីវិនព្រះយេស៊ូ ដែលប្រារព្ធធ្វើឡើងនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ជារៀងរាល់ថ្ងៃអង្គារ : ចាប់ពីម៉ោង ៩ ព្រឹក ដល់ ១២ថ្ងៃត្រង់ នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ មានទទួលពិនិត្យជំងឺកុមារ និងមនុស្សពេញវ័យលើប្រភេទជំងឺមួយចំនួន ដែលមានដូចជា ជំងឺដែលមានបញ្ហាមាត់ឆែប ស្បែករមេះ ឬជាប់គ្នា ដែលការពិនិត្យព្យាបាលនេះគឺធ្វើឡើងដោយគ្រូពេទ្យមកពីប្រទេសអ៊ីតាលី។
- នាឱកាសបុណ្យអុំទូកនេះ : ព្រះសហគមន៍ផ្សារតូចផ្តល់អង្ករចំនួន ២៥០គីឡូ ដល់សង្កាត់ឬស្សីកែវ ដើម្បីទទួលភ្ញៀវ។
- ពីថ្ងៃទី២៧ ដល់ទី២៩ វិច្ឆិកា : ក្រុមគូស្រករនឹងធ្វើការជួបជុំគ្នាដើម្បីរិះគិតអំពីជីវិតគូស្រករប្រពៃណី និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ព្រមទាំងដោះស្រាយបញ្ហាជាមួយគ្នា ដែលមានប្តី និងប្រពន្ធ ២៦គូចូលរួម។ ពិធីនេះនឹងប្រារព្ធធ្វើនៅព្រះសហគន៍កំពង់ចាម។
- ជារៀងរាល់ខែ : គ្រូអប់រំជំនឿនៅព្រះសហគមន៍កំពង់ចាម មានបើកវគ្គសិក្សាអំពីការបណ្តុះបណ្តាលការអប់រំជំនឿ ដែលមានរយៈពេល១ ឬ២ថ្ងៃ បង្រៀនដោយលោកបូជាចារ្យ។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្បូ អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ